## រាជរដ្ឋាភិបាលកម្ពុជា

# ទស្សនាទាន
# ស្តីពីទិសដៅយុទ្ធសាស្ត្រ
# នៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា
# ២០១៣-២០២០

រៀបចំដោយ
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## មុខកថា

ដោយសារមានចក្ខុវិស័យវែងឆ្ងាយ គួបផ្សំនឹងគោលនយោបាយត្រឹមត្រូវ និង មានយុទ្ធសាស្ត្រច្បាស់លាស់ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវសមិទ្ធផលធំៗមិនអាចកាត់ថ្លៃជាច្រើន ក្នុងការដឹកនាំប្រទេស ក្នុងរយៈកាលជាងពីរទសវត្សកន្លងទៅ ដោយមិនត្រឹមតែរក្សាបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានធ្វើឱ្យមានការវិវឌ្ឍរីកចម្រើនគួរជាទីមោទនៈ នៅលើគ្រប់វិស័យ, ទាំងវិស័យនយោបាយ, សេដ្ឋកិច្ច និង សង្គមទៀតផង។ ជាក់ស្តែង, ពីនីតិកាលមួយទៅនីតិកាលមួយទៀតជាបន្តបន្ទាប់, នយោបាយនៅកម្ពុជាកាន់តែឈានទៅរកភាពចាស់ទុំ ដែលធ្វើឱ្យការអនុវត្តលទ្ធិប្រជាធិបតេយ្យកាន់តែមានលក្ខណៈល្អប្រសើរឡើងជាលំដាប់ និង ធ្វើឱ្យសេដ្ឋកិច្ចមានកំណើនខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន ហើយអត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយជាងពាក់កណ្តាល គឺពីជាង ៤០% នៃប្រជាជន មកនៅត្រឹមក្រោម ២០%។ លើសពីនេះ កម្ពុជាបានទប់ទល់នឹងវិបត្តិដែលបានកើតឡើងផ្ទួនៗគ្នា ប្រកបដោយជោគជ័យនៅក្នុងអំឡុងឆ្នាំ ២០០៩-២០១១ នោះ គឺវិបត្តិកលិយុគសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលលោក, ទំនាស់ព្រំដែនកម្ពុជា-ថៃ និងគ្រោះមហន្តរាយធម្មជាតិជាបន្តបន្ទាប់។ ប្រការនេះ បញ្ជាក់ឱ្យឃើញថា កម្ពុជាមិនត្រឹមតែបាន និង កំពុងដើរលើផ្លូវត្រូវក្នុងការស្តារ, កសាង និងអភិវឌ្ឍប្រទេស ក្រោយពីប្រទេសត្រូវបានរំដោះឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ និងសង្គ្រាមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងប្រកបដោយវីរភាព, ហ៊ានធ្វើហ៊ានទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ដើម្បីបុព្វហេតុប្រទេសជាតិយ៉ាងពិតប្រាកដ។

ជោគជ័យ និងសមិទ្ធផលដ៏ធំធេងមិនអាចកាត់ថ្លៃបាននេះ គឺពិតជាមិនអាចកាត់ផ្តាច់ចេញពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានឡើយ ពីព្រោះការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមិនត្រឹមតែមានមុខងារក្នុងការស្វែងរកថវិកា, វិភាជថវិកា និង ធានាការប្រើប្រាស់ថវិកាប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានតួនាទីជាឃ្នាស់សេដ្ឋកិច្ច និងជាឧបករណ៍សម្រាប់បម្រើឱ្យគោលនយោបាយវិស័យសាធារណៈ និង គោលនយោបាយសេដ្ឋកិច្ចថែមទៀតផង។ ហេតុនេះហើយ បានជា **ថវិកា** ត្រូវបានឱ្យនិយមន័យថា ជាឧបករណ៍នៃ **គោលនយោបាយ** ។

ជាក់ស្តែង ក្នុងជីវិតជានាយករដ្ឋមន្ត្រីរបស់ខ្ញុំ គឺពិតជាគ្មានអ្វីធ្វើឱ្យខ្ញុំសប្បាយចិត្តជាងការដែលអាចលុបបំបាត់បានទាំងស្រុងនូវបំណុលសាច់ប្រាក់ និង ស្ថានភាពខ្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ ហើយឈានមកធ្វើការទូទាត់បានទាន់ពេលវេលាប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបានធ្វើឱ្យមានអតិរេកសាច់ប្រាក់ជាបន្តបន្ទាប់ដែលបានធ្វើឱ្យការអនុវត្តថវិកាកាន់តែអាចជឿទុកចិត្តបាន និង មានលទ្ធភាពបង្កើនចំណាយលើវិស័យអាទិភាពមួយចំនួនដូចជាវិស័យអប់រំ, សុខាភិបាល និង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ព្រមទាំងដោះស្រាយបាននូវវិបត្តិផ្សេងៗក្នុងអំឡុងឆ្នាំ ២០០៩-២០១១ និង ជាបណ្តើរៗ ឈានទៅតម្លើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ឱ្យបានកាន់តែសមរម្យ និង ប្រកបដោយសមធម៌។ សមិទ្ធផលទាំងនេះ គឺពិតជាបានមកដោយសារជោគជ័យនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស គឺការសម្រេចបានជាសារវន្តនូវគោលដៅជំហានទីមួយ ក្នុងចំណោមជំហានទាំងបួនដែលត្រូវធ្វើដំណើរឆ្ពោះទៅរកស្តង់ដារអន្តរជាតិនៃការរៀបចំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពោលគឺការផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬ ប្រព័ន្ធគ្រប់គ្រង

**ថវិកាផ្អែកលើធាតុចូល និង មធ្យការ ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬ សមិទ្ធកម្ម និង វិមធ្យការ** ដែលរាជរដ្ឋាភិបាលប្តេជ្ញាថា នឹងសម្រេចឱ្យបាននៅឆ្នាំ ២០២៥ ។

ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬ សមិទ្ធកម្ម គឺជាប្រព័ន្ធដែលផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងសកម្មភាពជាក់ស្តែង និង កម្មវិធីច្បាស់លាស់, ទៅនឹងគោលបំណងគោលនយោបាយអាទិភាពរបស់ក្រសួង-ស្ថាប័ន និង ជាពិសេសទៅនឹងគោលបំណងគោលនយោបាយតាមវិស័យ និង របៀបវារៈគោលនយោបាយរបស់រដ្ឋាភិបាល ដើម្បីធានាថា **ថវិកាជាតិ គឺពិតជាដើរតួនាទីជាឧបករណ៍នៃគោលនយោបាយរបស់រដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធប្រាកដមែន។** ពិតណាស់ថា ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដែលជាគោលដៅចម្បងនៃដំណាក់កាលទីពីរ ត្រូវតែសម្រេចបានជាមូលដ្ឋាននៅក្នុងដំណាច់ឆ្នាំ២០១៥ នេះ ទើបយើងអាចចាប់ផ្តើមដំណាក់កាលទីបី ដែលផ្តោតលើការកែទម្រង់មូលដ្ឋានគ្រឹះនៃប្រព័ន្ធថវិកានៅឆ្នាំ ២០១៦ ខាងមុខនេះបាន។ ដូច្នេះ ដើម្បីជាមគ្គុទ្ទេសក៍ និង ដើម្បីធានាចីរភាពនៃការងារកែទម្រង់ រាជរដ្ឋាភិបាលនីតិកាលទីបួននៃរដ្ឋសភាបានដាក់ចេញនូវ **ឯកសារស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០** ។ ឯកសារនេះ បានកំណត់ទិសដៅ និង យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ដែលជាស្នូលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពិសេសសម្រាប់ដំណាក់កាលទីបី និង ទីបួន និង ដែលត្រូវបន្តអនុវត្តជាជំហានៗ និង ជាដំណាក់ៗ ឆ្ពោះទៅរក **ការផ្លាស់ប្តូរជាបណ្តើរៗនូវប្រព័ន្ធគ្រប់គ្រងថវិកាកម្ពុជាពីការផ្តោតលើធាតុចូល និង មធ្យការ ទៅជាការផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និង វិមធ្យការ ឱ្យបានជោគជ័យនៅឆ្នាំ២០២០** ។ ការកែទម្រង់

ប្រព័ន្ធថវិកានេះ ផ្តោតអាទិភាពសំខាន់ទៅលើសមាសភាគសំខាន់បួននៃវដ្តថវិកា គឺការរៀបចំថវិកា, ការអនុម័តថវិកា, ការអនុវត្តថវិកា និងការត្រួតពិនិត្យតាមដានវាយតម្លៃលទ្ធផល។

ទិសដៅចម្បងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺការឈានទៅផ្លាស់ប្តូរប្រព័ន្ធទាំងមូល តាមរយៈការផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផ្អែកលើធាតុចូល និង មជ្ឈការ ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផ្អែកលើលទ្ធផល ឬ សមិទ្ធកម្ម និង វិមជ្ឈការ ហើយការផ្លាស់ប្តូរនេះ គឺពិតជាបាន និង កំពុងមានផលប៉ះពាល់ដល់កិច្ចប្រតិបត្តិការងារ, ដល់ការប្រើប្រាស់ និង គ្រប់គ្រងធនធានមនុស្ស, ដល់រចនាសម្ព័ន្ធគ្រប់គ្រង និង ចាត់តាំងស្ថាប័ន និង ដល់ការងារគ្រប់គ្រង ដែលជាការងារស្មុគស្មាញ និង ត្រូវការពេលវេលា ព្រមទាំងត្រូវការឆន្ទៈនយោបាយ និងបច្ចេកទេសខ្ពស់ និងជាពិសេសត្រូវការនូវការដឹកនាំ, ការគ្រប់គ្រង និង ការសម្របសម្រួលការងារកែទម្រង់ប្រកបដោយភាពហ្មត់ចត់, ភាពហ្មឹងម៉ាត់, ភាពអំណត់ និង ការព្យាយាមកម្រិតខ្ពស់ ព្រមទាំងត្រូវការនូវទិសដៅ ក៏ដូចជាយុទ្ធសាស្ត្រច្បាស់លាស់ និង យន្តការគ្រប់គ្រងត្រួតពិនិត្យជាប្រចាំប្រកបដោយភាពស័ក្តិសិទ្ធ និង ប្រសិទ្ធភាពខ្ពស់ ទើបអាចធានាសម្រេចបានជោគជ័យ ។ លើសពីនេះ ការកែទម្រង់នេះតម្រូវឱ្យមានកិច្ចសហការប្រកបដោយភាពជាម្ចាស់, ការទទួលខុសត្រូវខ្ពស់, និងបុរេសកម្មពីគ្រប់តួអង្គទាំងអស់ ជាពិសេស ការធានារក្សាឱ្យបាននូវសង្គតិភាព និងសុខដុមនីយកម្មរវាងការកែទម្រង់ធំៗ និងសំខាន់ៗទាំងបី ដែលមានលក្ខណៈជាការកែទម្រង់ប្រព័ន្ធនោះ គឺ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់វិមជ្ឈការ និង

វិសហមជ្ឈការក្នុងក្របខ័ណ្ឌនៃកម្មវិធីស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

លើសពីនេះទៀត បទពិសោធន៍ជាអន្តរជាតិបានបង្ហាញឱ្យឃើញថា ទោះជាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ គឺជាការងារសំខាន់ និងដើមខ្សែក៏ដោយ ប៉ុន្តែ ភាពជោគជ័យនៃប្រព័ន្ធថវិកាផ្អែកលើលទ្ធផលជាមួយនឹងប្រព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការ និង វិមជ្ឈការ ក៏អាស្រ័យទៅលើផ្នែកកណ្តាលខ្សែ និង ចុងខ្សែដែរ នោះ គឺការអនុវត្តថវិកា ឬ ការគ្រប់គ្រងហិរញ្ញវត្ថុ ដែលតម្រូវឱ្យមានការធ្វើតុល្យភាពអំណាចរវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង-ស្ថាប័នជំនាញ ក៏ដូចជារវាងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និង អង្គភាពជំនាញនានានៃក្រសួង-ស្ថាប័ន ដើម្បីធានាគណនេយ្យភាព និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់ និង ប្រកបដោយប្រសិទ្ធភាព ព្រមទាំងធានាឱ្យបាននូវការតាមដានវាយតម្លៃលទ្ធផលសម្រេចបាន ដែលជាផ្នែកដ៏សំខាន់ចុងក្រោយនៃវដ្តថវិកា នៅក្នុងប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬ សមិទ្ធកម្ម និង ជាធាតុចូលដ៏សំខាន់សម្រាប់វដ្តបន្ទាប់។ ម៉្យាងទៀត ប្រព័ន្ធនេះ តម្រូវឱ្យមានការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងសិទ្ធិអំណាច និង ការទទួលខុសត្រូវឱ្យបានច្បាស់លាស់ និង មានសង្គតិភាពទៅនឹងរចនាសម្ព័ន្ធនៃគោលនយោបាយដែលរួមមានគោលបំណងគោលនយោបាយ, កម្មវិធី និង អនុកម្មវិធី ព្រមទាំងចង្កោមសកម្មភាព ដែលមានសូចនាករ និង គោលដៅ សម្រាប់វាស់វែងលទ្ធផលនៅគ្រប់កម្រិតនីមួយៗ ។ ដូច្នេះ ដើម្បីអាចអនុវត្តប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផលបានពេញលេញ លុះត្រាតែមានព័ត៌មានច្បាស់លាស់, គ្រប់ជ្រុងជ្រោយ, លម្អិត, សុក្រឹត និង ទាន់ពេលវេលា ទើបអាចយកមកវិភាគ, វាយតម្លៃ និង ធ្វើជាមូលដ្ឋាន សម្រាប់ការវិភាជថវិកា និង ត្រួតពិនិត្យ តាមដានវាយតម្លៃលទ្ធផលបាន។

ការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជាបាន និង កំពុងដើរលើផ្លូវត្រូវ ហើយស្របទៅនឹងនិន្នាការនៃការកែទម្រង់ជាសកល ព្រមទាំងបាន និង កំពុងផ្តល់ផ្លែផ្កា និង វឌ្ឍនភាពគួរជាទីលើកទឹកចិត្ត ។ ទន្ទឹមនឹងនេះ វឌ្ឍនភាព និង បទ-ពិសោធន៍ ដែលទទួលបានកន្លងមកពិតជាបានផ្តល់នូវទស្សនៈ, ចំណេះដឹង និង មូលដ្ឋានដ៏រឹងមាំ ធ្វើឱ្យយើងមានជំនឿថា យើងពិតជាមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ការបន្តអនុវត្តការកែទម្រង់ប្រព័ន្ធថវិកាប្រកបដោយជោគជ័យ តាមទិសដៅយុទ្ធសាស្ត្រដែលបានកំណត់ ដើម្បីឈានទៅសម្រេចឱ្យបាននូវការផ្លាស់ប្តូរប្រព័ន្ធថវិកាកម្ពុជាទាំងស្រុង ពីប្រព័ន្ធថវិកាតាមបន្ទាត់មាតិកា និងការគ្រប់គ្រងផ្តោតលើធាតុចូល ទៅជាប្រព័ន្ធថវិកាកម្មវិធី និង ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល និង សមិទ្ធកម្មជាមួយនឹងវិមជ្ឈការនៅឆ្នាំ ២០២០ ដែលជាមូលដ្ឋានដ៏សំខាន់ចាំបាច់ និង ថែមទាំងជាកត្តាកំណត់ជោគជ័យនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល ។

ពិតណាស់ថា យើងក៏នឹងត្រូវជួបប្រទះនូវបញ្ហាប្រឈម, ការលំបាក និង ភាពស្មុគស្មាញមួយចំនួន ជាពិសេសសម្រាប់ការកែទម្រង់ទាំងបី ដែលមានលក្ខណៈជាការកែទម្រង់ប្រព័ន្ធ ។ ប៉ុន្តែ បើគិតអំពីអត្ថប្រយោជន៍ ដែលយើងទទួលបាន ហើយនឹងបន្តទទួលបានពីការអនុវត្តការកែទម្រង់ទាំងនេះ យើងច្បាស់ជាទទួលស្គាល់ថា វាពិតជាមានតម្លៃលើសលប់ ធៀបទៅនឹងការបង់ថ្លៃទាំងនេះ ដូចពាក្យថា ***"គ្មានលទ្ធផលណាដែលបានមកដោយមិនមានការបង់ថ្លៃនោះទេ ហើយក៏គ្មានការកែទម្រង់ណាដែលសម្រេចបានដោយមិនមានការលះបង់នោះដែរ"*** ។ ក្នុងស្មារតីនេះដែរ ខ្ញុំនៅតែចង់គូសបញ្ជាក់ម្តងហើយម្តងទៀតថា ***"កែទម្រង់គឺរស់ មិនកែទម្រង់គឺស្លាប់"*** ។ ពិតជាគ្មានការសង្ស័យទេថា ដំណើរការវិវត្តយ៉ាងលឿននៃសេដ្ឋកិច្ច, សង្គម និង បច្ចេកវិទ្យា នាសម័យសកលភាវូបនីយកម្ម

និង សមាហរណកម្ម មិនត្រឹមតែបាន និង កំពុងជំរុញទាំងបុគ្គល, ទាំងស្ថាប័ន, ទាំងវិស័យឯកជន, ទាំងវិស័យសាធារណៈ, ទាំងកម្រិតជាតិ, ទាំងកម្រិតតំបន់ និង ទាំងកម្រិតអន្តរជាតិ ឱ្យធ្វើប្រតិបត្តិការប្រកបដោយភាពរស់រវើក ព្រមទាំងត្រៀមលក្ខណៈជានិច្ច សម្រាប់ការកែលម្អ និង ការកែទម្រង់ឱ្យកាន់តែប្រសើរឡើងជាប្រចាំប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងតម្រូវឱ្យមានការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយ និង ទូលំទូលាយ ហួសពីព្រំសីមារបស់ខ្លួន ក្នុងការវិភាគ និង ការធ្វើសេចក្តីសម្រេចចិត្ត ទើបអាចធានាភាពប្រកួតប្រជែង និង ការអភិវឌ្ឍប្រកបដោយចីរភាពបាន។

*រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០១៥*

**នាយករដ្ឋមន្ត្រី**



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

## អារម្ភកថា

រាជរដ្ឋាភិបាលបានកំណត់ទិសដៅ និង បានប្តេជ្ញាកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ជាជំហានៗ ជាដំណាក់ៗ ឆ្ពោះទៅរកកម្រិតស្តង់ដារ និង ឧត្តមានុវត្តន៍អន្តរជាតិ តាមរយៈការដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង ត្រូវប្រើរយៈពេលវែង លើអភិក្រម ៤ ដំណាក់កាល ក្នុងនោះរួមមាន÷

**(១). ការកសាងភាពជឿទុកចិត្តលើថវិកា** ដែលបានប្រើពេល ៤ ឆ្នាំ (២០០៥-២០០៨) ដើម្បីសម្រេចបានជាមូលដ្ឋាន នោះគឺការពង្រឹងការគ្រប់គ្រង និង ការប្រមូលចំណូល, ការគ្រប់គ្រងសាច់ប្រាក់ និង ការកែលម្អការអនុវត្តចំណាយ,

**(២). ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ** ដែលកំពុងរំពឹងថា នឹងសម្រេចបានជាមូលដ្ឋាននៅក្នុងឆ្នាំ ២០១៥ (២០០៩-២០១៥) នោះគឺការដាក់ឱ្យអនុវត្តប្លង់គណនេយ្យថ្មី, មាតិកាថវិកាថ្មី, អង្គភាពថវិកា, ការកែលម្អកិច្ចប្រតិបត្តិការចំណាយ និង ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ,

**(៣). ការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** ដែលកំពុងរំពឹងថា នឹងត្រូវការពេលប្រមាណ ៥ ឆ្នាំ (២០១៥-២០២០) ដែលគ្រោងនឹងចាប់ផ្តើមនៅក្នុងឆ្នាំ ២០១៦ ជាមួយនឹងគោលដៅចម្បង និង ជាគន្លឹះនោះ គឺការកែទម្រង់ប្រព័ន្ធថវិកាទាំងមូល ពីប្រព័ន្ធផ្តោតលើធាតុចូល និង មជ្ឈការ ទៅប្រព័ន្ធផ្តោតលើលទ្ធផល និង វិមជ្ឈការ តាមរយៈការពង្រឹង និង ពង្រីកការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា, ការអនុវត្តថវិកាកម្មវិធី និង ការអនុវត្តអង្គភាព

ថវិកា ព្រមទាំងការពង្រឹងការរៀបចំគោលនយោបាយ, ការព្យាករណ៍ និង ការរៀបចំផែនការហិរញ្ញវត្ថុសាធារណៈ, និង

**(៤).ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម** ដែលកំពុងគ្រោងថា នឹងត្រូវការពេលប្រមាណ ៥ ឆ្នាំ (២០២១-២០២៥) ដើម្បីសម្រេចឱ្យបានជាមូលដ្ឋាននូវគណនេយ្យភាពសមិទ្ធកម្ម ដែលត្រូវចាប់ផ្ដើមត្រៀមលក្ខណៈជាបណ្ដើរៗ ពីដំណាក់កាលទី ៣ ទៅ នោះ គឺការរៀបចំក្របខ័ណ្ឌនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយផ្អែកលើសមិទ្ធកម្ម ដែលជាគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ជារួម កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូលនឹងត្រូវការពេលប្រមាណជាង ២០ ឆ្នាំ (២០០៥-២០២៥) ហើយកម្មវិធីកែទម្រង់នេះ គឺអាចវាយតម្លៃបានថាមានលក្ខណៈប្រាកដនិយម, ជាក់ស្ដែងនិយម និង ភាពជាម្ចាស់ ដែលនឹងធ្វើឱ្យការអនុវត្តថវិការបស់កម្ពុជា មានឧត្តមភាពប្រហាក់ប្រហែលនឹងបណ្ដាប្រទេសអភិវឌ្ឍន៍នៅលើសកលលោកនេះ ។

ជាការពិត បន្ទាប់ពីសម្រេចបានជោគជ័យជាសារវន្តនូវភាពជឿទុកចិត្តបានលើថវិកាដែលជាគោលដៅនៃដំណាក់កាលទី ១ មក ក្នុងដំណាក់កាលទី ២ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដែលត្រូវបានចាប់ផ្ដើមនៅដើមឆ្នាំ ២០០៩ ហើយកំពុងត្រូវបានជំរុញអនុវត្តបញ្ចប់ តាមរយៈការដាក់ឱ្យអនុវត្តប្លង់គណនេយ្យថ្មី, មាតិកាថវិកាថ្មី, កិច្ចប្រតិបត្តិការចំណាយថ្មី និង ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីអាចឈានទៅចាប់ផ្ដើមដំណាក់កាលទី ៣ នៅដើមឆ្នាំ ២០១៦។ កិច្ចការទាំងនេះ គឺជាការបន្តពង្រឹង និង ពង្រីកការអនុវត្តប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធនូវផែនការយុទ្ធសាស្ត្រថវិកា, ថវិកាកម្មវិធី និង

អង្គភាពថវិកា ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដែលជាគោលដៅចម្បងនៃដំណាក់កាលទី ៣ នេះគឺ **ការផ្លាស់ប្តូរជាបណ្តើរៗនូវប្រព័ន្ធគ្រប់គ្រងថវិកាកម្ពុជា ពីការផ្តោតលើធាតុចូល និង មធ្យោបាយទៅជាការផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និង វិមធ្យោបាយ ដែលត្រូវសម្រេចឱ្យបាននៅឆ្នាំ ២០២០ ។**

ពិតណាស់ថា ក្នុងការអនុវត្តជាក់ស្តែង មកដល់បច្ចុប្បន្នរដ្ឋាភិបាលនៃប្រទេសភាគច្រើន នៅតែមានការលំបាកក្នុងការធានា និង ធ្វើឱ្យសាធារណជនមានជំនឿថា ថវិការបស់រដ្ឋាភិបាល គឺពិតជាឧបករណ៍របស់គោលនយោបាយហើយការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល គឺពិតជាដើម្បីបម្រើឱ្យប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធប្រាកដនោះ ។ ម៉្យាងទៀតសូម្បីតែការគោរពគោលការណ៍ថវិកាដ៏សំខាន់ ៣ គឺវិន័យថវិកា (រក្សាតុល្យភាព និង ចីរភាព), ប្រសិទ្ធភាពវិភាជថវិកា (ធានាការវិភាជចំគោលដៅអាទិភាព) និង ប្រសិទ្ធភាពបច្ចេកទេសនៃការប្រើប្រាស់ថវិកា (ធានាការប្រើប្រាស់ថវិកាប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធ) ក៏រដ្ឋាភិបាលនៃបណ្តាប្រទេសមួយចំនួនមកដល់បច្ចុប្បន្ននៅតែពុំទាន់អាចគោរពបានពេញលេញនៅឡើយ ។ ជាក់ស្តែង មកដល់ពេលនេះ រដ្ឋាភិបាលនៃប្រទេសមួយចំនួន នៅតែប្រឈមនឹងការធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ឬ/ និង ទៅនឹងសកម្មភាព ឬ/ និង សមិទ្ធកម្ម ទោះជាប្រទេសអភិវឌ្ឍន៍ដែលមានប្រព័ន្ធគ្រប់គ្រងថវិកាប្រកបដោយកម្រិតស្តង់ដារខ្ពស់ , ប្រើប្រាស់បច្ចេកវិទ្យាទាន់សម័យ និង មានសមត្ថភាពស្ថាប័ន និង ធនធានមនុស្សកម្រិតខ្ពស់ហើយក៏ដោយ ។ ជាលទ្ធផល បញ្ហាប្រឈមនេះ បានបង្កជាវិបត្តិបំណុលសាធារណៈ និង ឱនភាពថវិកាខ្ពស់

ហួសហេតុ ព្រមទាំងចំណាយខ្ពស់ហួសព្រំដែនលើវិស័យមួយចំនួន ដូចជាវិស័យយោធា និង ប្រព័ន្ធសុវត្ថិភាពសង្គម ដែលបានធ្វើឱ្យប្រទេសមួយចំនួននោះ ធ្លាក់ទៅក្នុងវិបត្តិហិរញ្ញវត្ថុសាធារណៈធ្ងន់ធ្ងរ ដែលវិបត្តិនេះ បានកើតឡើងដោយសារតែការធ្វេសប្រហែសក្នុងការគោរពគោលការណ៍ថវិកាដ៏សំខាន់ទាំង ៣ នេះ ។

ដោយឡែកសម្រាប់កម្ពុជា ក្រោមការដឹកនាំប្រកបដោយទស្សនវិស័យត្រឹមត្រូវ និង ចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាមួយនឹងស្មារតីហ៊ានធ្វើហ៊ានទទួលខុសត្រូវ និង ប្រកបដោយភាពជាម្ចាស់, ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាពិតជាបានប្រតិបត្តិ និងដើរលើគន្លងផ្លូវយ៉ាងត្រឹមត្រូវ ឆ្លើយតបទៅនឹងគោលនយោបាយ និង របៀបវារៈរបស់រាជរដ្ឋាភិបាល និង សេចក្តីត្រូវការជាក់ស្តែងរបស់សង្គមជាតិ ទោះជាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ពុំទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅតាមស្តង់ដារអន្តរជាតិក៏ដោយ ។ ជាក់ស្តែង នៅក្នុងកម្រិតម៉ាក្រូ យើងមានគោលនយោបាយ, យុទ្ធសាស្ត្រ និង យន្តការគ្រប់គ្រងបានយ៉ាងល្អ ទាំងផ្នែកម៉ាក្រូសេដ្ឋកិច្ច និង ទាំងផ្នែកហិរញ្ញវត្ថុសាធារណៈ ដែលធ្វើឱ្យកម្ពុជាមិនត្រឹមតែអាចរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យវិស័យទាំងពីរនេះមានវឌ្ឍនភាព និង រីកចម្រើនជាលំដាប់ ទោះជាកម្ពុជាស្ថិតក្នុងស្ថានភាពប្រឈមដ៏លំបាក ដូចជាការប្រឈមនឹងកលយុគសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០០៩-២០១១ ក៏ដោយ ។ ប៉ុន្តែ អ្វីដែលជាបញ្ហាប្រឈមនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់យើងនោះ គឺការកំណត់គោលនយោបាយ និង យុទ្ធសាស្ត្រ ឱ្យកាន់តែច្បាស់លាស់ ព្រមទាំងការរៀបចំកម្មវិធី និងសកម្មភាពជាក់ស្តែងជាមួយនឹងសូចនាករ និង គោលដៅប្រកប

ដោយសុក្រឹតភាព និង ភាពប្រាកដនិយម ដើម្បីធានាបម្រើឱ្យគោលនយោបាយ អាទិភាព និង យុទ្ធសាស្រ្តតាមវិស័យនានា ទាំងនៅថ្នាក់ក្រោមជាតិ និង នៅថ្នាក់ជាតិ ។ ទន្ទឹមនេះ ការរៀបចំរចនាសម្ព័ន្ធស្ថាប័ន និង ក្របខ័ណ្ឌគណនេយ្យភាពច្បាស់លាស់នៅក្នុងរចនាសម្ព័ន្ធស្ថាប័ន គឺជាបញ្ហាប្រឈមដែលត្រូវតែដោះស្រាយទន្ទឹមគ្នា ទើបអាចធានាកិច្ចប្រតិបត្តិការរបស់ក្រសួង-ស្ថាប័ន ក៏ដូចជាកិច្ចប្រតិបត្តិ-ការរបស់រាជរដ្ឋាភិបាលទាំងមូលឱ្យដំណើរការប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធបាន ។

ក្របខ័ណ្ឌប្រព័ន្ធថវិកាជាតិឆ្នាំ ២០២០ ដែលត្រូវបានកំណត់នៅក្នុង **ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០** គឺជាប្រព័ន្ធថវិកាផ្អែកលើលទ្ធផល ឬ សមិទ្ធកម្មដែលបានចង្អុលបង្ហាញអំពីរចនាសម្ព័ន្ធគោលនយោបាយ (គោលបំណងគោលនយោបាយ, កម្មវិធី, អនុកម្មវិធី, ចង្កោមសកម្មភាព និង សកម្មភាព) ច្បាស់លាស់ និង រចនា-សម្ព័ន្ធគ្រប់គ្រងស្ថាប័ន (កម្រិតដឹកនាំ, គ្រប់គ្រង និង បច្ចេកទេស) សមស្របព្រមទាំងមានការកំណត់សិទ្ធិអំណាច និង ការទទួលខុសត្រូវច្បាស់លាស់នៅគ្រប់កម្រិត ។ លើសពីនេះ ដើម្បីធ្វើឱ្យថវិកាក្លាយជាឧបករណ៍ពិតប្រាកដនៃគោល-នយោបាយចាំបាច់ត្រូវផ្សារភ្ជាប់ថវិកាប្រចាំឆ្នាំទៅនឹងគោលបំណងគោលនយោ-បាយតាមវិស័យ និង របៀបវារៈរបស់រាជរដ្ឋាភិបាល ដែលប្រព័ន្ធថវិកានេះ នឹងត្រូវប្រើប្រាស់ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រព័ន្ធឯកភាព, សង្គតិភាព, ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធ ក្នុងការគ្រប់គ្រងថវិកា ពិសេសដើម្បីធានាការគោរពតាមគោលការណ៍គ្រឹះនៃថវិកាទាំង១១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ម៉្យាងទៀត ថ្វីត្បិតតែទិសដៅ និង យុទ្ធសាស្ត្រនេះ ផ្តោតជាសំខាន់ទៅលើការកែលម្អ និង ការផ្លាស់ប្តូរជាជំហានៗនៃប្រព័ន្ធថវិកាថ្នាក់ជាតិ ប៉ុន្តែ មូលដ្ឋាននេះ ក៏នឹងត្រូវយកទៅរៀបចំជាទិសដៅ និង យុទ្ធសាស្ត្រសម្រាប់ការកែលម្អ និង ផ្លាស់ប្តូរជាជំហានៗនៃប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ ជាពិសេសការកំណត់ឱ្យបានត្រឹមត្រូវ និង ច្បាស់លាស់អំពីសិទ្ធិអំណាច និង ការទទួលខុសត្រូវក្នុងដំណាក់កាលទាំង ៤ នៃវដ្តថវិកា (ការរៀបចំថវិកា, ការអនុវត្តម័តថវិកា, ការអនុវត្តថវិកា និង ការតាមដានវាយតម្លៃលទ្ធផល) នៅគ្រប់ថ្នាក់ទាំង ៣ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ និង គ្រប់កម្រិតនៃថ្នាក់នីមួយៗ។

ជារួម ការកែទម្រង់ប្រព័ន្ធថវិកាបានក្លាយជាស្នូលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល។ ក្នុងស្មារតីនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងបន្តជំរុញការងារកែទម្រង់ប្រព័ន្ធថវិកា ពិសេសការកំណត់ទិសដៅ និង យុទ្ធសាស្ត្រសម្រាប់ដំណាក់កាលបន្ទាប់ដែលនឹងត្រូវផ្អែកលើមូលដ្ឋាននៃ **ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០** ដែលត្រូវបានអនុម័ត និង ដាក់ឱ្យអនុវត្តដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅចុងត្រីមាសទី៤ ក្នុងឆ្នាំ ២០១៣ កន្លងទៅ។ ទស្សនាទាននេះបាន កំណត់ទិសដៅ និង យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ដែលត្រូវបន្តអនុវត្តជាជំហានៗជាដំណាក់ៗ ដើម្បីធានាដល់ **ការផ្លាស់ប្តូរជាបណ្តើរៗនូវប្រព័ន្ធគ្រប់គ្រងថវិកាកម្ពុជាពីការផ្តោតលើធាតុចូល និង មជ្ឈការ ទៅជាការផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និង វិមជ្ឈការ** ឱ្យបានជោគជ័យតាមការគ្រោងទុក នៅឆ្នាំ ២០២០ ពេលពីការកែ

លម្អសមាសភាគសំខាន់ទាំង៤ នៃវដ្តថវិកា។ ទន្ទឹមនឹងនេះ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬ សមិទ្ធកម្មនេះ អាចអនុវត្ត និង សម្រេចបានតាមគោលដៅ គឺទាមទារឱ្យមានសមត្ថភាពមន្ត្រី និង ស្ថាប័នសមស្រប, មានប្រព័ន្ធប្រតិបត្តិការការងារប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធ និងជាពិសេសត្រូវមានប្រព័ន្ធគ្រប់គ្រងត្រួតពិនិត្យ, តាមដាន និង វាយតម្លៃលទ្ធផលប្រកបដោយតម្លាភាព, គណនេយ្យភាព និង ការទទួលខុសត្រូវច្បាស់លាស់។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្នុងនាមជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខ្ញុំសូមគោរពសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែផ្តល់ការណែនាំ, ចង្អុលបង្ហាញដោយផ្ទាល់ និង ជាប្រចាំដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ដល់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចបាននូវសមិទ្ធផលធំៗជាបន្តបន្ទាប់ ។ ទន្ទឹមនឹងនេះ ខ្ញុំសូមគោរពថ្លែងអំណរគុណ និង ដឹងគុណចំពោះឯកឧត្តម **កិត្តិសេដ្ឋាបណ្ឌិត គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និង ជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានខិតខំដឹកនាំ និង ជំរុញការរៀបចំ **ឯកសារគោលនយោបាយស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០** រហូតបានសម្រេចនៅចុងនីតិកាលទី៤ ហើយបានទទួលការឯកភាពដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដាក់ឱ្យអនុវត្តនៅក្នុង

ខែ មិថុនា ឆ្នាំ ២០១៣ និង ត្រូវបានបន្តជំរុញអនុវត្តនៅក្នុងនីតិកាលទី ៥ នេះ តាមរយៈ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** របស់រាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ដោយមានការចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង-ស្ថាប័ន, ប្តេជ្ញាថានឹងបន្តដឹកនាំ និង ជំរុញការអនុវត្តការកែទម្រង់ប្រព័ន្ធថវិកាដោយផ្អែកលើទស្សនាទាននេះ រហូតសម្រេចបានជោគជ័យ ទៅតាមដំណាក់កាលនីមួយៗ ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៥*

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រង**
**ហិរញ្ញវត្ថុសាធារណៈ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# I- សេចក្តីផ្តើម

១- តាមនិយមន័យ **ថវិកា** គឺជាឧបករណ៍នៃ **គោលនយោបាយ** ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង រដ្ឋាភិបាលនៃប្រទេសភាគច្រើន មកដល់បច្ចុប្បន្ននៅតែមានការលំបាកក្នុងការធានា និងធ្វើឱ្យសាធារណជនមានជំនឿថា ថវិការបស់រដ្ឋាភិបាល គឺពិតជាឧបករណ៍របស់គោលនយោបាយ ហើយការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល គឺពិតជាដើម្បីបម្រើឱ្យប្រជាពលរដ្ឋប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពប្រាកដមែន។ ម៉្យាងទៀត សូម្បីតែការគោរពគោលការណ៍ថវិកាដ៏សំខាន់ ៣ គឺវិន័យថវិកា (រក្សាតុល្យភាព និងចីរភាព) ប្រសិទ្ធភាពវិភាជថវិកា (ធានាការវិភាជចំគោលដៅអាទិភាព) និងប្រសិទ្ធភាពបច្ចេកទេសនៃការប្រើប្រាស់ថវិកា (ធានាការប្រើប្រាស់ថវិកាប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាព) ក៏រដ្ឋាភិបាលនៃបណ្តាប្រទេសមួយចំនួនមកដល់បច្ចុប្បន្ន នៅតែពុំទាន់អាចគោរពបានពេញលេញនៅឡើយ។ ជាក់ស្តែង ប្រទេសភាគច្រើនមកដល់ពេលនេះ នៅតែប្រឈមនឹងការធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ឬ/និង ទៅនឹងសកម្មភាព ឬ/និង សមិទ្ធកម្ម ទោះជាសម្រាប់ប្រទេសអភិវឌ្ឍន៍ ដែលមានប្រព័ន្ធគ្រប់គ្រងថវិកាប្រកបដោយកម្រិតស្តង់ដារអន្តរជាតិ ប្រើប្រាស់បច្ចេកវិទ្យាទាន់សម័យ និងមានសមត្ថភាពស្ថាប័ន និងធនធានមនុស្សកម្រិតខ្ពស់ក៏ដោយ។ តួយ៉ាងដូចជា បញ្ហាវិបត្តិបំណុលសាធារណៈ និងឱនភាពថវិកាខ្ពស់ហួសហេតុនៃបណ្តាប្រទេសមួយចំនួន ព្រមទាំងការចំណាយខ្ពស់ហួសព្រំដែនលើវិស័យមួយចំនួនដូចជា វិស័យយោធា

និងប្រព័ន្ធសុវត្ថិភាពសង្គម ដែលបានធ្វើឱ្យប្រទេសទាំងនោះធ្លាក់ទៅក្នុងវិបត្តិហិរញ្ញវត្ថុសាធារណៈធ្ងន់ធ្ងរ ដោយសារតែការធ្វេសប្រហែសក្នុងការគោរពគោលការណ៍ថវិកាដ៏សំខាន់ទាំង ៣ ដូចបានគូសបញ្ជាក់ខាងលើ។

២- ទោះជាយ៉ាងណា បច្ចុប្បន្នប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាដែលកំពុងពេញនិយម ហើយដែលប្រទេសភាគច្រើនបាន និងកំពុងប្រឹងប្រែងកសាងឆ្ពោះទៅរក ឬ បាន និងកំពុងបន្តកែលម្អឱ្យកាន់តែប្រសើរឡើងតាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនោះ គឺ **ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម** (Result or Performance Based Public Finance Management or Budgeting System)។ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្មនេះ គឺជាប្រព័ន្ធដែលផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងសកម្មភាពជាក់ស្តែង និងកម្មវិធីច្បាស់លាស់ ទៅនឹងគោលបំណងគោលនយោបាយអាទិភាពរបស់ក្រសួង ស្ថាប័ន និងជាពិសេសទៅនឹងគោលបំណងគោលនយោបាយតាមវិស័យ និងរបៀបវារៈគោលនយោបាយថ្នាក់ជាតិរបស់រដ្ឋាភិបាល ដើម្បីធានាថា **ថវិកាជាតិពិតជាដើរតួនាទីជាឧបករណ៍នៃគោលនយោបាយរបស់រដ្ឋាភិបាលប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពប្រាកដមែន។**

៣- ស្របតាមនិន្នាការជាសកលនេះ កម្ពុជាបានប្តេជ្ញាធ្វើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួនឆ្ពោះទៅរកស្តង់ដារអន្តរជាតិ **ពោលគឺការផ្លាស់ប្តូរជាបណ្តើរៗពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រង**

**ថវិកាផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ** តាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាកម្មវិធីរយៈពេលវែង មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអនុវត្តតាមយុទ្ធសាស្ត្រ៤ ជំហាន ឬ/និង៤ ដំណាក់កាលគឺ *(១)ការបង្កើនភាពជឿទុកចិត្តលើថវិកា (២)ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ (៣)ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង (៤)ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម*។ ដំណាក់កាលទី១ ត្រូវបានចាប់ផ្តើមដាក់ឱ្យអនុវត្តនៅចុងឆ្នាំ២០០៤ និងត្រូវបានអនុវត្តពេញលេញនៅឆ្នាំ២០០៥ ហើយត្រូវបានបញ្ចប់ដោយជោគជ័យជាមួយនឹងការប្រកាសដាក់ឱ្យអនុវត្តដំណាក់កាលទី២ នៅចុងឆ្នាំ២០០៨ ហើយដែលគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០១៥ បន្ទាប់ពីការដាក់ឱ្យអនុវត្តជំហានទី១ នៃប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុបានចប់សព្វគ្រប់។ ដំណាក់កាលទី៣ នឹងត្រូវដាក់ឱ្យអនុវត្តព្រមជាមួយនឹងការបញ្ចប់ដំណាក់កាលទី២ នៅចុងឆ្នាំ ២០១៥ ជាមួយនឹងការចាប់ផ្តើមជំហានទី១ នៃការកែទម្រង់ប្រព័ន្ធថវិកានៅដើមឆ្នាំ២០១៥ ដែលនឹងត្រូវដាក់ឱ្យអនុវត្តពេញលេញនៅឆ្នាំ២០២០ ហើយដែលការកែទម្រង់ប្រព័ន្ធថវិកានេះនឹងក្លាយជាកម្លាំងចលករដ៏សំខាន់សម្រាប់ដំណាក់កាលទី៣ ដែលគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២០ ជាមួយនឹងការដាក់ឱ្យអនុវត្តដំណាក់កាលទី៤ ដែលសង្ឃឹមថាអាចនឹងបញ្ចប់ជាស្ថាពរនូវគោលដៅទាំងបួននៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូលនៅក្នុងឆ្នាំ២០២៥។

៤- ដូច្នេះ ឯកសារនេះមានគោលដៅកំណត់ទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជាដែលជាស្នូលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសសម្រាប់ដំណាក់កាលទី ៣ និងទី ៤ និងដែលត្រូវបន្តអនុវត្តជាជំហានៗ និងជាដំណាក់ៗ ដើម្បីឈានដល់**ការផ្លាស់ប្តូរជាបណ្តើរៗនូវប្រព័ន្ធគ្រប់គ្រងថវិកាកម្ពុជាពីការផ្តោតលើធាតុចូលនិងមធ្យោបាយ ទៅជាការផ្តោតលើលទ្ធផល ឬសមិទ្ធកម្មនិងវិមជ្ឈការឱ្យបានជោគជ័យតាមការគ្រោងទុកពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២០** ពោលគឺការកែលម្អទៅលើដំណាក់កាលសំខាន់ទាំងបួននៃវដ្តថវិកា គឺការរៀបចំថវិកា ការអនុម័តថវិកា ការអនុវត្តថវិកា និងការត្រួតពិនិត្យតាមដានវាយតម្លៃលទ្ធផល។ ទន្ទឹមនឹងនេះ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្មនេះ អាចអនុវត្តទៅបានសម្រេចតាមគោលដៅទាមទារឱ្យមានសមត្ថភាពមន្ត្រី និងស្ថាប័នសមស្រប មានប្រព័ន្ធប្រតិបត្តិការការងារប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាព និងជាពិសេស មានប្រព័ន្ធគ្រប់គ្រង ត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលប្រកបដោយតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវច្បាស់លាស់ ស័ក្តិសិទ្ធ និងប្រសិទ្ធិភាព។ បណ្តាចំណុចសំខាន់ និងបញ្ហាទាំងនេះ គឺជាកម្មវត្ថុ និងសមត្ថកម្មនៃឯកសារ**ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជាឆ្នាំ២០១៣-២០២០** ដែលត្រូវបានគូសបញ្ជាក់ និងពន្យល់លម្អិតនៅក្នុងមាតិកាសំខាន់៤ គឺ *(១)ក្របខ័ណ្ឌនៃប្រព័ន្ធថវិកាជាតិឆ្នាំ២០២០ (២)ទិសដៅ និងយុទ្ធសាស្ត្រអនុវត្តឆ្ពោះទៅរកប្រព័ន្ធថវិកាឆ្នាំ២០២០ (៣)លទ្ធផល និងបទពិសោធន៍នៃការកែទម្រង់ប្រព័ន្ធថវិកា និង (៤)បណ្តាកត្តាកំណត់ជោគជ័យនៃការកែទម្រង់*។

## II. ក្របខ័ណ្ឌនៃប្រព័ន្ធថវិកាជាតិឆ្នាំ២០២០

### ២.១- ប្រព័ន្ធថវិកាជាតិឆ្នាំ២០២០

៥- ប្រព័ន្ធថវិកាជាតិឆ្នាំ២០២០ នឹងត្រូវបានកំណត់តាមរយៈការកែលម្អទៅលើដំណាក់កាលទាំង៤ នៃវដ្តថវិកាគឺ ការរៀបចំថវិកា ការអនុម័តថវិកា ការអនុវត្តថវិកា និងការតាមដានវាយតម្លៃលទ្ធផល និងសមិទ្ធកម្មដូចខាងក្រោម÷

១- *__ការរៀបចំថវិកា:__* ផែនការយុទ្ធសាស្រ្តថវិការបស់ក្រសួង ស្ថាប័ន ដែលមានកំណត់គោលបំណងគោលនយោបាយ និងសូចនាករជាមួយនឹងគោលដៅ គឺជាផែនការថវិកា៣ ឆ្នាំរំកិល និងជាឯកសារផ្លូវការ ដែលអនុម័តដោយគណៈរដ្ឋមន្ត្រី។ ឯកសារនេះ គឺជាមូលដ្ឋានសម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំ និងជាមូលដ្ឋានសម្រាប់ការតាមដានវាយតម្លៃលទ្ធផល និងសមិទ្ធកម្មរបស់ក្រសួង ស្ថាប័ន។ ថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន នីមួយៗនឹងត្រូវរៀបចំដោយផ្អែកលើ និងវិភាជទៅតាមរចនាសម្ព័ន្ធគោលនយោបាយរបស់ខ្លួន ពោលគឺគោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព និងទៅតាមរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័នគឺ អគ្គនាយកដ្ឋាន នាយកដ្ឋាន និងការិយាល័យ ឬអង្គភាពក្រោមឱវាទ ដែលគ្រប់កម្រិតនីមួយៗសុទ្ធតែមានសូចនាករ និងគោលដៅសម្រាប់វាស់វែងលទ្ធផល និងសមិទ្ធកម្មរបស់ខ្លួន។ ទន្ទឹមនឹងនេះ ឥណទានថវិកាទាំងនោះ នឹងត្រូវកត់ត្រាទៅតាមចំណាត់ថ្នាក់ចំនួន ៦ ដែលបញ្ជាក់អំពីភូមិសាស្រ្ត រដ្ឋបាល មុខងារ កម្មវិធី សេដ្ឋកិច្ច និងប្រភពមូលនិធិយ៉ាងច្បាស់លាស់ ដែលពេលនោះការរៀបចំថវិកា និងការបូកសរុបថវិកាព្រមទាំងការរៀបចំសៀវភៅថវិកានឹងត្រូវធ្វើឡើងតាមរយៈប្រព័ន្ធព័ត៌មានវិទ្យា

ទាំងស្រុង។ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំដែលរាជរដ្ឋាភិបាលត្រូវដាក់ជូនអង្គការនីតិបញ្ញត្តិអនុម័តពីនឹងត្រូវរៀបចំ និងវិភាជទៅតាមគោលបំណងគោលនយោបាយ និងកម្មវិធី ជាមួយនឹងសូចនាករ និងគោលដៅសម្រាប់វាស់វែងលទ្ធផល និងសមិទ្ធកម្មរបស់រាជរដ្ឋាភិបាលដោយភ្ជាប់ជាមួយនឹងផែនការយុទ្ធសាស្ត្រថវិកា៣ ឆ្នាំរំកិល និងឯកសារលម្អិតសម្រាប់កម្មវិធីនីមួយៗ ដើម្បីជាអំណះអំណាង និងគាំទ្រដល់ការការពារគោលបំណងគោលនយោបាយនីមួយៗ។ ដូច្នេះ ថវិកាប្រចាំឆ្នាំនឹងឆ្លុះបញ្ចាំងអំពីការផ្សារភ្ជាប់ទៅនឹងគោលនយោបាយតាមវិស័យ និងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈតាមរយៈផែនការយុទ្ធសាស្ត្រថវិកា និងក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ហើយដែលគោលនយោបាយតាមវិស័យ និងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈត្រូវបានរៀបចំដោយផ្អែកលើគោលនយោបាយជាតិ (យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ) ដូចមានបង្ហាញក្នុងដ្យាក្រាម ១ ខាងក្រោម។ លើសពីនេះទៅទៀត ដ្យាក្រាម ២ ខាងក្រោមបង្ហាញអំពីទំនាក់ទំនងរវាងរចនាសម្ព័ន្ធគោលនយោបាយ (គោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព) និងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន (កម្រិតដឹកនាំ កម្រិតគ្រប់គ្រង និងកម្រិតបច្ចេកទេស) ជាមួយនឹងការកំណត់យ៉ាងច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវប្រកបដោយគណនេយ្យភាព និងតម្លាភាព។

**២- *ការអនុម័តថវិកា:*** ការអនុម័តថវិកានឹងត្រូវផ្លាស់ប្តូរទាំងស្រុងពីការអនុម័តលើប្រភេទនិងជំពូកទៅជាការអនុម័តលើគោលបំណងគោលនយោ-

បាយ កម្មវិធី និងសូចនាករជាមួយនឹងគោលដៅ។ ដូច្នេះ អង្គការនីតិបញ្ញត្តិនឹងផ្តោតការពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ទៅលើលទ្ធផលនៃគោលបំណងគោលនយោបាយ និងកម្មវិធីប្រសើរជាងការផ្តោតលើប្រភេទ និងជំពូកចំណាយដូចដែលកំពុងអនុវត្តបច្ចុប្បន្ន។ ទន្ទឹមនឹងនេះ អង្គការនីតិបញ្ញត្តិក៏នឹងទទួលបាននូវឯកសារ ព័ត៌មាន និងតួលេខលម្អិត គ្រប់ជ្រុងជ្រោយសម្រាប់ការវិភាគ ពិនិត្យ និងពិភាក្សាប្រកបដោយតម្លាភាព គណនេយ្យភាព និងគុណភាពក្នុងការអនុម័តថវិកាប្រចាំឆ្នាំ។ ដើម្បីងាយយល់អំពីការផ្លាស់ប្តូរមូលដ្ឋាននៃការរៀបចំ និងអនុម័តថវិកានេះ តារាងទី ១ ខាងក្រោមបង្ហាញអំពីការផ្លាស់ប្តូរពីការវិភាជ និងអនុម័តថវិកាតាមជំពូក និងប្រភេទទៅជាការវិភាជ និងអនុម័តថវិកាតាមគោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដែលមានសូចនាករ និងគោលដៅច្បាស់លាស់នៅគ្រប់កម្រិតសម្រាប់តាមដានវាយតម្លៃលទ្ធផល និងសមិទ្ធកម្មដែលសម្រេចបាន។

៣- ***ការអនុវត្តថវិកា:*** ការអនុវត្តថវិកានឹងត្រូវធ្វើវិសហមជ្ឈការ និងវិមជ្ឈការឱ្យស្របទៅនឹងប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ពិសេសគឺការផ្លាស់ប្តូរពីប្រព័ន្ធត្រួតពិនិត្យហិរញ្ញវត្ថុទៅជាការតាមដាន វាយតម្លៃលទ្ធផល និងសមិទ្ធកម្មទាំងរវាងនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ទាំងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នជំនាញនៅក្នុងរដ្ឋាភិបាល និងទាំងរវាងនាយកដ្ឋានហិរញ្ញវត្ថុ និងនាយកដ្ឋានជំនាញនៅក្នុងក្រសួង ស្ថាប័ននីមួយៗ។ ទន្ទឹមនឹងនេះ ប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់នឹងត្រូវធ្វើតាមរយៈប្រព័ន្ធព័ត៌មានវិទ្យា និងតាមរយៈប្រព័ន្ធធនាគារ។ ការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យានឹងត្រូវ

អនុវត្តពេញលេញ កិច្ចប្រតិបត្តិការអនុវត្តថវិកាសម្រាប់ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល និងសមិទ្ធកម្មនឹងត្រូវបានអនុវត្តពេញលេញ ច្បាប់លទ្ធកម្មសាធារណៈនឹងត្រូវបានអនុវត្តពេញលេញ និងការគ្រប់គ្រងសាច់ប្រាក់ប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពនឹងត្រូវសម្រេចឱ្យបាន។ ដូច្នេះ ការអនុវត្តថវិកានឹងមានលក្ខណៈសាមញ្ញ ប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពខ្ពស់ ហើយឆ្លើយតបទៅនឹងប្រសិទ្ធភាពបច្ចេកទេសនៃថវិកាគឺភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពនៃចំណាយ។

៤- ***ការតាមដានវាយតម្លៃលទ្ធផល និងសមិទ្ធកម្ម:*** ប្រព័ន្ធតាមដានវាយតម្លៃលទ្ធផល និងសមិទ្ធកម្មប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពនៅគ្រប់កម្រិតត្រូវតែបង្កើត ជាពិសេសរវាងនីតិបញ្ញត្តិ និងនីតិប្រតិបត្តិរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នជំនាញនៅក្នុងរដ្ឋាភិបាល និងប្រព័ន្ធតាមដាន វាយតម្លៃលទ្ធផល និងសមិទ្ធកម្មនៅក្នុងផ្ទៃក្នុងរបស់ក្រសួងស្ថាប័ននីមួយៗ។ ទន្ទឹមនឹងនេះ ប្រព័ន្ធ ឬយន្តការរៀបចំរបាយការណ៍ជាប្រចាំសម្រាប់ផ្ទៃក្នុង និងសម្រាប់ផ្សព្វផ្សាយជាសាធារណៈក៏ត្រូវបង្កើតឱ្យមានប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពផងដែរ ដើម្បីបង្កើនគណនេយ្យភាព និងតម្លាភាពចំពោះប្រជាពលរដ្ឋ។

**ដ្យាក្រាមទី១**

**ទំនាក់ទំនងរវាង គោលនយោបាយជាតិ គោលនយោបាយតាមវិស័យ**

**ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងថវិកាប្រចាំឆ្នាំ**




សំគាល់ ៖

(១) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំអនុម័តដោយនីតិបញ្ញត្តិ។

(២) គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច/គោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយតាមវិស័យគឺត្រូវធ្វើដោយស្ថាប័នថ្នាក់ជាតិ និងសម្រាប់ជាតិទាំងមូល។

(៣) ផ្អែកលើ(១)និង(២) ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំក្របខ័ណ្ឌចំណូល និងចំណាយរយៈពេលមធ្យម និងផែនការយុទ្ធសាស្ត្រថវិកាដើម្បីសុំការអនុម័ត និងសម្រាប់ជាមូលដ្ឋាននៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ខ្លួន ដើម្បីសុំការអនុម័តតាមលំដាប់លំដោយនៃឋានានុក្រម ដើម្បីដាក់បញ្ចូលក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំរបស់ជាតិទាំងមូល និងសុំការអនុម័តពីអង្គការនីតិបញ្ញត្តិរៀងរាល់ឆ្នាំ។


ដ្យាក្រាមទី២
ទំនាក់ទំនងរវាងខ្សែសង្វាក់គ្រប់គ្រង ខ្សែសង្វាក់គោលនយោបាយ និងសិទ្ធិអំណាច
ខ្សែសង្វាក់គ្រប់គ្រង
សិទ្ធិអំណាច និងការទទួលខុសត្រូវ
ខ្សែសង្វាក់គោលនយោបាយ
កម្រិតដឹកនាំ និងកំណត់គោលនយោបាយ (កម្រិតទី១: ក្រសួង ស្ថាប័ន)
កំណត់គោលនយោបាយ
គោលបំណងគោលនយោបាយ/ យុទ្ធសាស្ត្រ/ កម្មវិធី
កម្រិតគ្រប់គ្រងបច្ចេកទេស និងកំណត់យុទ្ធសាស្ត្រ/ កម្មវិធី (កម្រិតទី២: អគ្គលេខាធិការ/ អគ្គនាយកដ្ឋាន)
កំណត់យុទ្ធសាស្ត្រ/កម្មវិធី
យុទ្ធសាស្ត្រ/ កម្មវិធី
កម្រិតបច្ចេកទេស និងកំណត់អនុកម្មវិធី/ សកម្មភាព (កម្រិតទី៣: នាយកដ្ឋាន/ សមមូល)
កំណត់អនុកម្មវិធី/ចង្កោមសកម្មភាព
អនុកម្មវិធី/ ចង្កោមសកម្មភាព
កម្រិតបច្ចេកទេស និងអនុវត្តសកម្មភាព (កម្រិតទី៤/៥...: បណ្តាអង្គភាពក្រោមឱវាទ)
កំណត់/ អនុវត្តសកម្មភាព
សកម្មភាព

| តារាង១: ការផ្លាស់ប្តូរមូលដ្ឋាននៃការរៀបចំថវិកា និងការអនុម័តថវិកា | | | | |
|---|---|---|---|---|
| មូលដ្ឋានបច្ចុប្បន្ន | | មូលដ្ឋានថ្មី | | |
| ប្រភេទ/ជំពូក | តម្រូវការថវិកា (លានរៀល) | គោលនយោបាយ | សូចនាករ/គោលដៅ | តម្រូវការថវិកា (លានរៀល) |
| ប្រភេទ ១ | ១០០ ០០០ | (១) គោលនយោបាយទី១ | សូចនាករទី១: សូចនាករទី២: | ៩៤ ០០០ |
| *៦០* | *៤១ ០០០* | *១.១- កម្មវិធីទី ១* | សូចនាករទី១: សូចនាករទី២: | *៤៧ ០០០* |
| *៦១* | *១៤ ០០០* | ១.១.១- អនុកម្មវិធី | | |
| *៦២* | *១៣ ០០០* | ១.១.១.១- ចង្កោមសកម្មភាព | | |
| *៦៤* | *៣២ ០០០* | *១.២- កម្មវិធីទី ២* | សូចនាករទី១: សូចនាករទី២: | *៤៧ ០០០* |
| ប្រភេទ ២ | - | ១.២.១- អនុកម្មវិធី | | |
| *៦៦* | - | ១.២.១.១- ចង្កោមសកម្មភាព | | |
| ប្រភេទ ៣ | ២២ ០០០ | (២) គោលនយោបាយទី២ | សូចនាករទី១: សូចនាករទី២: សូចនាករទី៣: | ១៤១ ០០០ |
| *៦៥* | *២២ ០០០* | *២.១- កម្មវិធីទី ៣* | សូចនាករទី១: សូចនាករទី២: | *៤៧ ០០០* |
| ប្រភេទ ៤ | ១១៣ ០០០ | ២.១.១- អនុកម្មវិធី | | |
| *៦៣* | *១១៣ ០០០* | ២.១.១.១- ចង្កោមសកម្មភាព | | |
| | | *២.២- កម្មវិធីទី ៤* | សូចនាករទី១: សូចនាករទី២: | *៤៧ ០០០* |
| | | ២.២.១- អនុកម្មវិធី | | |
| | | ២.២.១.១- ចង្កោមសកម្មភាព | | |
| | | *២.៣- កម្មវិធីទី ៥* | សូចនាករទី១: សូចនាករទី២: | *៤៧ ០០០* |
| | | ២.៣.១- អនុកម្មវិធី | | |
| | | ២.៣.១.១- ចង្កោមសកម្មភា | | |
| សរុប | ២៣៥ ០០០ | គោលនយោបាយ ២/ កម្មវិធី៥ | សូចនាករ ៤/១០ | ២៣៥ ០០០ |

## ២.២- ប្រព័ន្ធថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**៦-** ប្រព័ន្ធថវិកាជាតិឆ្នាំ២០២០ ដែលបានកំណត់ខាងលើ គឺជាប្រព័ន្ធថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្មដែលទាមទារឱ្យមានរចនាសម្ព័ន្ធគោលនយោបាយ (គោលបំណងគោលនយោបាយ កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព) ច្បាស់លាស់ និងរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន (កម្រិតដឹកនាំគ្រប់គ្រង និងបច្ចេកទេស) សមស្រប ព្រមទាំងមានការកំណត់សិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់លាស់នៅគ្រប់កម្រិតដូចមានបង្ហាញនៅក្នុងដ្យាក្រាម ២ ខាងលើ ទើបអាចអនុវត្តទៅប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពបាន។ លើសពីនេះទៅទៀត ដ្យាក្រាម១ បានបង្ហាញអំពីទំនាក់ទំនងនៃការផ្សារភ្ជាប់ថវិកាប្រចាំឆ្នាំទៅនឹងគោលនយោបាយ ដែលគោលនយោបាយទាំងនោះអាចមានច្រើនកម្រិត និងត្រូវបានអនុម័តដោយកម្រិតខុសៗគ្នាថែមទៀតផង ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំត្រូវអនុម័តដោយអង្គការនីតិបញ្ញត្តិ។ ដូច្នេះប្រព័ន្ធថវិកានេះ គួរតែត្រូវបានប្រើប្រាស់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រព័ន្ធមានឯកភាព សង្គតិភាព ភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងថវិកា និងជាពិសេសត្រូវគោរពតាមគោលការណ៍គ្រឹះនៃថវិកាទាំង ១១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនឹងនេះ ក្នុងការកំណត់ប្រព័ន្ធថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិគួរយកចិត្តទុកដាក់លើបណ្តាចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម÷

១- ក្នុងពេលដែលរាជរដ្ឋាភិបាល កំពុងរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសការផ្ទេរមុខងារ និងវិសហមជ្ឈការមុខងារ សិទ្ធិអំណាច និងការទទួលខុសត្រូវជាបណ្តើរៗទៅថ្នាក់រាជធានី-ខេត្ត ថ្នាក់ស្រុក-ខណ្ឌ និងថ្នាក់ឃុំសង្កាត់ គួរតែយកមូលដ្ឋាននៃវគ្គក្រោម ១ និង ២ ខាងលើ ដើម្បីធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ពិសេសទំនាក់ទំនងរវាងគោលនយោបាយថ្នាក់ក្រោមជាតិ (រាជធានី-ខេត្ត ក្រុង -ស្រុក-ខណ្ឌ និងឃុំ-សង្កាត់) ជាមួយនឹងគោលនយោបាយថ្នាក់ជាតិតាមវិស័យ (ក្រសួង-ស្ថាប័ន) និងគោលនយោបាយជាតិ (កម្រិតប្រទេសទាំងមូល) ជាមួយនឹងការរៀបចំរចនា-សម្ព័ន្ធគ្រប់គ្រង និងរចនាសម្ព័ន្ធគោលនយោបាយ ព្រមទាំងការកំណត់សិទ្ធិអំណាច និងការទទួលខុសត្រូវឱ្យបានត្រឹមត្រូវច្បាស់លាស់ ដើម្បីធានាប្រសិទ្ធ-ភាព និងភាពស័ក្តិសិទ្ធនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- ម៉្យាងទៀត ថ្វីត្បិតតែទិសដៅ និងយុទ្ធសាស្ត្រខាងក្រោមនេះផ្តោតជាសំខាន់ទៅលើការកែលម្អ និងការផ្លាស់ប្តូរជាជំហានៗនៃប្រព័ន្ធថវិកាថ្នាក់ជាតិ ប៉ុន្តែមូលដ្ឋាននេះពិតជាអាចយកទៅរៀបចំជាទិសដៅ និងយុទ្ធសាស្ត្រសម្រាប់ការកែលម្អ និងផ្លាស់ប្តូរជាជំហានៗនៃប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិបាន ពិសេសការកំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវនៅក្នុងដំណាក់កាលទាំង ៤ នៃវដ្តថវិកា (ការរៀបចំថវិកា ការអនុម័តថវិកា ការអនុវត្តថវិកា និងការតាមដានវាយតម្លៃលទ្ធផល) នៅគ្រប់ថ្នាក់ទាំង ៣ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រប់កម្រិតនៃថ្នាក់នីមួយៗ ដើម្បីធានាភាពស័ក្តិ-សិទ្ធ ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃប្រព័ន្ធគ្រប់គ្រងថ្នាក់ក្រោមជាតិ។

៣- ដើម្បីធានាឯកត្តភាព ភាពគ្រប់ជ្រុងជ្រោយ សង្គតិភាព សុខដុមនីយកម្ម ពិសេស ដើម្បីអាចបូកសរុបបានទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវតែរៀបចំឱ្យមានការឯកភាពទាំងប្រព័ន្ធ និងការគ្រប់គ្រងគណនេយ្យហិរញ្ញវត្ថុ និងថវិកាដូចជាការរៀបចំប្លង់គណនេយ្យ និងចំណាត់ថ្នាក់ថវិកាឯកភាព និងការរៀបចំប្រព័ន្ធរបាយការណ៍គណនេយ្យហិរញ្ញវត្ថុឯកភាពជាដើម។ ជាពិសេស ថ្វីត្បិតតែការអនុវត្តថវិកានឹងត្រូវធ្វើវិសហមជ្ឈការ និងវិមជ្ឈការទៅតាមលំដាប់ថ្នាក់ និងកម្រិតនីមួយៗ ប៉ុន្តែត្រូវរៀបចំមូលដ្ឋាននៃការរៀបចំ និងការអនុម័តថវិកាឱ្យមានការឯកភាព ព្រមទាំងត្រូវដាក់ឆ្លង និងសុំការអនុម័តតាមលំដាប់លំដោយនៃឋានានុក្រម ជាមួយនឹងការរៀបចំក្របខ័ណ្ឌ និងយន្តការតាមដានវាយតម្លៃលទ្ធផល និងសមិទ្ធកម្មឯកភាព ដើម្បីធានាតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃប្រព័ន្ធថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ជាតិទាំងមូល។

ដូច្នេះ ផ្អែកតាមក្របខ័ណ្ឌនៃប្រព័ន្ធថវិកាថ្មីខាងលើ និងទិសដៅយុទ្ធសាស្ត្រដែលបានគូសបញ្ជាក់ខាងក្រោម បញ្ជាក់ឱ្យឃើញយ៉ាងច្បាស់អំពីភាពចាំបាច់នៃការធានាសង្គតិភាព និងភាពស៊ីសង្វាក់គ្នារវាងការកែទម្រង់ដែលមានលក្ខណៈជាការកែទម្រង់ប្រព័ន្ធទាំង៣ គឺ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការកែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេស ទាមទារឱ្យការកែទម្រង់ទាំង៣ នេះ រៀបចំទិសដៅយុទ្ធសាស្ត្រ និងផែនការសកម្មភាពឱ្យប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នាដើម្បីធានាការគាំទ្រនិងបំពេញឱ្យគ្នាទៅវិញទៅមកប្រកបដោយភាពស័ក្តិសិទ្ធនិងប្រសិទ្ធភាព ទើបអាចធានាការសម្រេចបានជោគជ័យនៃការកែទម្រង់នីមួយៗបាន។

## III- ទិសដៅ និងយុទ្ធសាស្ត្រឆ្ពោះទៅរកប្រព័ន្ធថវិកាឆ្នាំ២០២០

**៧-** តាមទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដែលបានកំណត់តាំងពីចុងឆ្នាំ២០០៤ នៅពេលដាក់ឱ្យអនុវត្តដំណាក់កាលទី ១ នោះគឺនឹងសម្រេចឱ្យបាននូវការលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យដល់កម្រិតស្តង់ដារអន្តរជាតិ ឬតំបន់ឱ្យបានត្រឹមឆ្នាំ២០១៥ តាមរយៈយុទ្ធសាស្ត្រ ៤ ជំហាន ឬ/និង ៤ ដំណាក់កាល។ ប៉ុន្តែ ឆ្លងតាមបទពិសោធន៍នៃការអនុវត្តរយៈកាល ៨ ឆ្នាំកន្លងទៅនេះ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ នឹងមិនអាចសម្រេចបានចប់សព្វគ្រប់មុនឆ្នាំ ២០២៥ បានទេ។ ដូច្នេះ មានន័យថាការកែទម្រង់នេះនឹងត្រូវការពេលវេលាប្រហែល ២១ ឆ្នាំ (២០០៥-២០២៥) ពោលគឺ (១) ៤ ឆ្នាំ (២០០៥-២០០៨)សម្រាប់ការសម្រេចបានជាសារវន្តនូវភាពជឿទុកចិត្តបានលើថវិកាដែលជាគោលដៅនៃជំហានទី១ ហើយយុទ្ធសាស្ត្រជាគន្លឹះនោះគឺ ការពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អការអនុវត្តចំណាយ (២) ត្រូវការពេលវេលាប្រមាណ ៧ ឆ្នាំ (២០០៩-២០១៥) សម្រាប់ការសម្រេចឱ្យបានជាសារវន្តនូវគណនេយ្យភាពហិរញ្ញវត្ថុដែលជាគោល-ដៅនៃជំហានទី២ ហើយដែលយុទ្ធសាស្ត្រជាគន្លឹះនោះគឺ ការដាក់ឱ្យអនុវត្តប្លង់គណនេយ្យ និងមាតិកាថវិកាថ្មី អង្គភាពថវិកា និងប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (៣) ត្រូវការពេលវេលាប្រមាណ ៦ ឆ្នាំ (២០១៥-២០២០) ដើម្បីសម្រេចឱ្យបានជាសារវន្តនូវការផ្សារភ្ជាប់ថវិកាទៅនឹងគោល-នយោបាយដែលជាគោលដៅនៃជំហានទី ៣ ហើយដែលយុទ្ធសាស្ត្រជាគន្លឹះនោះគឺការកែទម្រង់ប្រព័ន្ធថវិកា និង (៤) ត្រូវការពេលវេលាប្រមាណ ៥ ឆ្នាំ

(២០២១-២០២៥) ដើម្បីសម្រេចឱ្យបានជាសារវន្តនូវគណនេយ្យភាពសមិទ្ធកម្ម ដែលជាគោលដៅនៃជំហានទី៤ ហើយដែលយុទ្ធសាស្ត្រជាគន្លឹះនោះគឺការអនុវត្ត ពេញលេញនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកលើសមិទ្ធកម្មដែល ជាគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ៣.១- ទិសដៅនៃការកែទម្រង់ថវិកា២០១៣-២០២០

៨- ផ្អែកលើក្របខ័ណ្ឌទិសដៅ និងយុទ្ធសាស្ត្រនៃការកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈដូចបានគូសបញ្ជាក់ខាងលើឃើញថា ការងារកែទម្រង់ ប្រព័ន្ធថវិកាគឺជាស្នូលនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល ដូច្នេះ ដើម្បីធានាឱ្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អាចសម្រេចបានជោគជ័យតាមការគ្រោងទុក និងប្រកបដោយប្រសិទ្ធភាព និង ចីរភាព ទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកាជាតិនៅកម្ពុជាត្រូវបានកំណត់ដូច ខាងក្រោម÷

***១- បន្តពង្រឹង និងពង្រីកការអនុវត្តសាកល្បងថវិកាកម្មវិធី ដើម្បីឆ្ពោះ ទៅការអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ២០២០*** គឺនៅពេលនោះប្រព័ន្ធ គ្រប់គ្រងថវិកាត្រូវបានផ្លាស់ប្តូរទាំងស្រុងពីប្រព័ន្ធថវិកាផ្អែកលើបន្ទាត់មាតិកា ទៅ ជាប្រព័ន្ធថវិកាផ្អែកលើកម្មវិធីជាមួយនឹងការអនុវត្តពេញលេញនូវប្រព័ន្ធគ្រប់គ្រង ផ្អែកលើលទ្ធផល និងសមិទ្ធកម្ម។

***២- បន្តពង្រឹង និងកែលម្អការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ដើម្បី ឆ្ពោះទៅអនុវត្តក្របខ័ណ្ឌចំណូល និងចំណាយរយៈពេលមធ្យម និងប្រព័ន្ធគណ-នេយ្យភាពចំពោះសមិទ្ធកម្មពេញលេញនៅឆ្នាំ២០២០*** គឺមានន័យថាផែនការ

យុទ្ធសាស្ត្រថវិកាដែលរួមមានក្របខ័ណ្ឌចំណូល និងចំណាយរយៈពេលមធ្យមនេះ ត្រូវបានរៀបចំដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងក្របខ័ណ្ឌគោលនយោបាយតាមវិស័យ ដែលមានសង្គតិភាពទៅនឹងគោលនយោបាយជាតិ (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណ) ព្រមទាំងមានសូចនាករ និងគោលដៅច្បាស់លាស់ សម្រាប់វាស់វែងលទ្ធផលសម្រេចបានរបស់ក្រសួងស្ថាប័នទីមួយៗ។ ទំនាក់ទំនងរវាងគោលនយោបាយជាតិទៅនឹងថវិកាប្រចាំឆ្នាំមានបង្ហាញនៅក្នុងដ្យាក្រាម១ ខាងលើ។

*៣- បន្តរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា ដើម្បីឆ្ពោះទៅអនុវត្តប្រព័ន្ធគណនេយ្យភាពផ្ទៃក្នុងក្រសួង ស្ថាប័នឱ្យបានពេញលេញនៅឆ្នាំ២០២០* ពោលគឺការពង្រឹងការទទួលខុសត្រូវរបស់អង្គភាពនីមួយៗក្នុងការអនុវត្តមុខងារ និងសកម្មភាពការងាររបស់ខ្លួនដែលត្រូវបានកំណត់ច្បាស់លាស់ ព្រមទាំងមានសូចនាករ និងគោលដៅជាក់លាក់នៅក្នុងរចនាសម្ព័ន្ធនៃគោលនយោបាយរបស់ក្រសួង ស្ថាប័នទីមួយៗដូចមានបង្ហាញនៅក្នុងដ្យាក្រាម២ ខាងលើ។

*៤- បន្តរៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗនូវមាតិកាថវិកាថ្មី ប្លង់គណនេយ្យថ្មី និងការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវគណនេយ្យភាពហិរញ្ញវត្ថុពេញលេញមុនឆ្នាំ២០២០* ពោលគឺជាប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុមួយប្រកបដោយភាពច្បាស់លាស់ សុក្រឹត គ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា។

*៥- បន្តរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មី (ការផ្តល់ធានាចំណាយ ការធ្វើលទ្ធកម្មសាធារណៈ និងការទូទាត់) ដែលស័ក្តិសិទ្ធ មានប្រសិទ្ធ-*

*ភាព និងសមស្របទៅនឹងប្រព័ន្ធថវិកាកម្មវិធីឱ្យបានមុនឆ្នាំ ២០២០* ពោលគឺជាប្រព័ន្ធអនុវត្តថវិកាដែលផ្តោតលើលទ្ធផល និងមានលក្ខណៈវិសហមជ្ឈការ និងវិមជ្ឈការក្នុងកម្រិតមួយសមស្រប។

*៦- ត្រៀមលក្ខណៈជាបណ្តើរៗ ដើម្បីឈានទៅធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ឱ្យបានមុនឆ្នាំ២០២០* សម្រាប់ការអនុវត្តពេញលេញនូវប្រព័ន្ធថវិកាកម្មវិធី និងប្រព័ន្ធគ្រប់គ្រងដោយផ្តោតលើលទ្ធផល និងមានលក្ខណៈវិសហមជ្ឈការ និងវិមជ្ឈការ។

## ៣.២- យុទ្ធសាស្ត្រឆ្ពោះទៅកែប្រព័ន្ធថវិកាឆ្នាំ២០២០

*៩-* ដើម្បីអាចសម្រេចបានតាមទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកាជាតិ ក៏ដូចជាការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដូចបានកំណត់ខាងលើ រាជរដ្ឋាភិបាលនឹងត្រូវដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម÷

*១- ពង្រឹងការអនុវត្ត និងបង្កើនប្រសិទ្ធភាព ផែនការយុទ្ធសាស្ត្រថវិកៈ* ពីឆ្នាំ២០១៣ ដល់២០១៤ ត្រូវត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាកន្លងមក ដើម្បីស្វែងរកចំណុចខ្លាំង និងចំណុចខ្សោយ ហើយរៀបចំយុទ្ធសាស្ត្រពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា។ ឆ្នាំ២០១៥ ដាក់ផែនការយុទ្ធសាស្ត្រថវិកាឆ្លងគណៈរដ្ឋមន្ត្រីអនុម័ត (ចាប់ផ្តើមពីក្រសួង ១០ ដែលអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា) ដើម្បីបង្កើនក្របខ័ណ្ឌគតិយុត្ត និងធ្វើឱ្យផែនការថវិកា ៣ ឆ្នាំរំកិលនេះក្លាយជាឯកសារផ្លូវការ និងជាឯកសារគោលសម្រាប់ចង្អុលទិសដល់ការរៀបចំ និងការវិភាជថវិកាប្រចាំឆ្នាំ ដើម្បីធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ បន្ទាប់

មក បន្តពង្រឹងការអនុវត្តនេះរៀងរាល់ឆ្នាំ ហើយធ្វើការត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ២០១៧ ឬ២០១៨ ដើម្បីកែលម្អបន្ថែម និងត្រៀមលក្ខណៈសម្រាប់ការអនុវត្តពេញលេញនូវប្រព័ន្ធថវិកាកម្មវិធី និងការគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល និងសមិទ្ធកម្ម ពោលគឺគោលបំណងគោលនយោបាយ និងកម្មវិធីដែលមានសូចនាករ និងគោលដៅនៅក្នុងផែនការយុទ្ធសាស្ត្រថវិកានឹងត្រូវតាមដានវាយតម្លៃលទ្ធផល និងសមិទ្ធកម្មចាប់ពីឆ្នាំ២០២០ តទៅ។

***២- ពង្រឹង និងពង្រីកការអនុវត្តសាកល្បងថវិកាកម្មវិធី:*** ពីឆ្នាំ២០១៣ ដល់២០១៤ ត្រូវបន្តពង្រឹង និងបង្កើនសមត្ថភាពនៃការអនុវត្តថវិកាកម្មវិធីពិសេសរៀបចំយុទ្ធសាស្ត្រ សម្រាប់ការឈានទៅអនុវត្តថវិកាកម្មវិធីពេញលេញនៃក្រសួងដែលកំពុងសាកល្បងទាំង៨។ ឆ្នាំ២០១៥ ដាក់ឱ្យក្រសួងដែលត្រូវអនុវត្តអង្គភាពថវិកាទាំង ១០ អនុវត្តថវិកាកម្មវិធីពេញលេញ ហើយណែនាំ និងជំរុញឱ្យក្រសួងដទៃទៀតចាប់ផ្តើមអនុវត្តថវិកាកម្មវិធីពេញលេញដោយស្ម័គ្រចិត្ត។ បន្ទាប់មក បន្តពង្រឹងការអនុវត្ត និងជំរុញឱ្យក្រសួងស្ម័គ្រចិត្តចូលរួមអនុវត្តថវិកាកម្មវិធីពេញលេញ ហើយធ្វើការត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ ២០១៧ ឬ២០១៨ ដើម្បីកែលម្អបន្ថែម និងត្រៀមលក្ខណៈសម្រាប់ការអនុវត្តពេញលេញនូវប្រព័ន្ធថវិកាកម្មវិធី និងការគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល និងសមិទ្ធកម្ម ពោលគឺការផ្លាស់ប្តូរប្រព័ន្ធថវិកាទាំងស្រុងពីថវិកាផ្អែកលើបន្ទាត់មាតិកា ទៅជាប្រព័ន្ធថវិកាកម្មវិធី និងការគ្រប់គ្រងដោយផ្អែកលើលទ្ធផល និងសមិទ្ធកម្មចាប់ពីឆ្នាំ២០២០ តទៅ។

***៣- ដាក់ឱ្យអនុវត្តអង្គភាពថវិកា:*** ពីឆ្នាំ២០១៣ ដល់២០១៤ ត្រូវបន្តរៀបចំ និងត្រៀមលក្ខណៈសម្រាប់ក្រសួង ១០ (ក្រសួងថវិកាកម្មវិធីទាំង ៨

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការនិងដឹកជញ្ជូន) ដែលត្រូវចាប់ផ្តើមសាកល្បងអនុវត្តអង្គភាពថវិកា។ ឆ្នាំ២០១៥ ដាក់ឱ្យក្រសួងទាំង ១០ អនុវត្តអង្គភាពថវិកាសាកល្បង។ បន្ទាប់មក បន្តពង្រឹងការអនុវត្ត និងជំរុញឱ្យក្រសួងដទៃចូលរួមដោយស្ម័គ្រចិត្តក្នុងការអនុវត្តអង្គភាពថវិកា ហើយធ្វើការត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ២០១៧ ឬ២០១៨ ដើម្បីកែលម្អបន្ថែម និងត្រៀមលក្ខណៈសម្រាប់ការអនុវត្តពេញលេញនូវអង្គភាពថវិកានៅគ្រប់ក្រសួង ស្ថាប័ន ជាមួយនឹងការអនុវត្តពេញលេញនូវប្រព័ន្ធថវិកាកម្មវិធី និងការគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល និងសមិទ្ធកម្មចាប់ពីឆ្នាំ២០២០ តទៅ។

*៤- ដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី ប្លង់គណនេយ្យថ្មី និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ:* ពីឆ្នាំ២០១៣ ដល់២០១៤ ត្រូវបន្តរៀបចំ និងត្រៀមលក្ខណៈសម្រាប់ការដាក់ឱ្យអនុវត្តជំហានដំបូងនៃមាតិកាថវិកាថ្មី ប្លង់គណនេយ្យថ្មី និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ។ ឆ្នាំ ២០១៥ ដាក់ឱ្យអនុវត្តជំហានដំបូងនៃមាតិកាថវិកាថ្មី ប្លង់គណនេយ្យថ្មី និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ។ បន្ទាប់មក បន្តពង្រឹងការអនុវត្តជំហានដំបូងនេះ ហើយធ្វើការត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ២០១៧ ឬ ២០១៨ ដើម្បីកែលម្អបន្ថែម និងត្រៀមលក្ខណៈសម្រាប់ការអនុវត្តពេញលេញនូវមាតិកាថវិកាថ្មី ប្លង់គណនេយ្យថ្មី និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុជាមួយនឹងការអនុវត្តពេញលេញនូវប្រព័ន្ធថវិកាកម្មវិធី និងការគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល និងសមិទ្ធកម្មចាប់ពីឆ្នាំ២០២០ តទៅ។

*៥- ដាក់ឱ្យអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មី:* ពីឆ្នាំ២០១៣ ដល់២០១៤ ត្រូវបន្តរៀបចំ និងត្រៀមលក្ខណៈសម្រាប់ការអនុវត្តជំហានដំបូងនៃប្រព័ន្ធអនុវត្ត

ថវិកាថ្មី។ ឆ្នាំ២០១៥ ដាក់ឱ្យអនុវត្តជំហានដំបូងនៃប្រព័ន្ធអនុវត្តថវិកាថ្មីក្នុងក្រប-ខ័ណ្ឌនៃជំហានដំបូងនៃប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ។ បន្ទាប់មក បន្តពង្រីង និងកែលម្អការអនុវត្តជំហានដំបូងនៃប្រព័ន្ធអនុវត្តថវិកានេះ ហើយធ្វើការត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ ២០១៧ ឬ២០១៨ ដើម្បីកែលម្អបន្ថែម និងត្រៀមលក្ខណៈសម្រាប់ការអនុវត្តពេញលេញនូវប្រព័ន្ធអនុវត្តថវិកាថ្មីជាមួយនឹងការអនុវត្តពេញលេញនូវប្រព័ន្ធថវិកាកម្មវិធី និងការគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល និងសមិទ្ធកម្មចាប់ពីឆ្នាំ២០២០ តទៅ។

## IV. លទ្ធផល និងបទពិសោធន៍នៃការកែទម្រង់ថវិកា

### ៤.១- លទ្ធផលនៃការកែទម្រង់ថវិកាកន្លងមក

**១០-** ជោគជ័យជំហានទីមួយនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសការកសាងបានជាមូលដ្ឋាននូវ**ភាពជឿទុកចិត្តលើថវិកា** ដែលជាគោលដៅចម្បងនៃដំណាក់កាលទី១ បានធ្វើឱ្យស្ថានភាពនៃការអនុវត្តថវិកាត្រូវបានផ្លាស់ប្តូរពី ***ការបង្គរបំណុលសាច់ប្រាក់ពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ មកជាការជម្រះបំណុលសាច់ប្រាក់ទាំងស្រុង និងការសន្សំសាច់ប្រាក់ឱ្យមានអតិរេកពីមួយឆ្នាំទៅមួយឆ្នាំ***។ ការផ្លាស់ប្តូរនេះបានធ្វើឱ្យការអនុវត្តថវិកាមានភាពរលូន និងបង្កើនភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពក្នុងការអនុវត្តថវិកាបានមួយកម្រិត តាមរយៈការបើកផ្តល់បានទាន់ពេលវេលា និងទៅតាមកម្មវិធីចំណាយ សម្រាប់បម្រើឱ្យការអនុវត្តសកម្មភាពការងាររបស់ក្រសួងស្ថាប័ន។ ប្រការដែលកាន់តែមិនអាចបំភ្លេចបាននោះគឺលទ្ធផលនៃភាពជឿទុកចិត្តបានលើថវិកានេះ បានផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលអាចស្រោចស្រង់ និងទប់ស្កាត់បាននូវឥទ្ធិពលនៃវិបត្តិកលិយុគហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសកលលោក ព្រមទាំងវិបត្តិព្រំដែន និងគ្រោះធម្មជាតិ ដែលត្រូវបានកើតឡើងព្រមៗគ្នានៅក្នុងអំឡុងឆ្នាំ ២០០៩ ដល់ ២០១១ ដោយមិនបាច់រត់ទៅខ្ចីបុលគេ ឬបោះពុម្ពក្រដាសប្រាក់ ដែលអាចនឹងគំរាមកំហែងដល់ការបាត់បង់តុល្យភាព ស្ថិរភាព និងចីរភាពថវិកា ក៏ដូចជាស្ថិរភាព និងចីរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ចនោះទេ។

១១-ពិតណាស់ថា ការងារដែលត្រូវបានផ្ដោតជាសំខាន់នៅក្នុងដំណាក់កាលទីមួយនោះគឺ ការងារកែលម្អ និងការពង្រឹង*ការអនុវត្តថវិកាដែលជាផ្នែកកណ្ដាលនៃវដ្ដថវិកា* (ឬអាចថានៅកណ្ដាលខ្សែ) ពោលគឺ ការកែលម្អ និងការពង្រឹងការប្រមូល និងការគ្រប់គ្រងចំណូល និងការកែលម្អ និងការពង្រឹងការអនុវត្តចំណាយ ដែលរួមមានការផ្ដល់ធានាចំណាយ ការធ្វើកិច្ចលទ្ធកម្ម ការគ្រប់គ្រងបំណុល ការគ្រប់គ្រងសាច់ប្រាក់ និងការទូទាត់ ហើយការងារទាំងនេះភាគច្រើនស្ថិតក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាក់ស្ដែង ការអនុវត្តចំណូលបានកាន់តែប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ពោលគឺចំណូលត្រូវបានកើនឡើងជារៀងរាល់ឆ្នាំក្នុងមធ្យមភាគប្រមាណជាង ២០% ដែលបានផ្ដល់លទ្ធភាពឱ្យរាជរដ្ឋាភិបាល អាចបន្តដំឡើងបៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធបន្តពង្រឹង និងពង្រីកសេវាសាធារណៈសំខាន់ៗដូចជាសេវាអប់រំ និងសុខាភិបាល ព្រមទាំងបន្តបង្កើនតម្រូវការចំណាយលើការវិនិយោគ ពិសេសហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ ប្រការនេះ បានធ្វើឱ្យទំហំថវិកាកើនឡើងជារៀងរាល់ឆ្នាំក្នុងមធ្យមភាគប្រមាណជាង ១០% ដែលធ្វើឱ្យទំហំថវិកាជាមធ្យមភាគប្រចាំឆ្នាំក្នុងនីតិកាលទី៤ នេះឡើងដល់ជាង ១០ ៤០០ ពាន់លានរៀលក្នុងមួយឆ្នាំ ធៀបទៅនឹង ២ ៤០០ ពាន់លាន រៀល ក្នុងនីតិកាលទី២ និង ៥ ២០០ ពាន់លានរៀល ក្នុងនីតិកាលទី៣។ ទន្ទឹមនឹងនេះ ការកៀរគរហិរញ្ញប្បទានពីក្រៅប្រទេសក៏ត្រូវបានកើនឡើងជិត ៨ដង ពីនីតិកាលទី១ មកនីតិកាលទី៤ គឺពីមធ្យមភាគប្រចាំឆ្នាំជាង ៤២៦ ពាន់លានរៀល នៅក្នុងនីតិកាលទី១ មក ៣ ១០០ ពាន់លានរៀល នៅក្នុងនីតិកាលទី៤។

**១២-** ទោះជាយ៉ាងណា ការពង្រឹងនិងការបង្កើនភាពជឿទុកចិត្តលើថវិកា ត្រូវបាន និងកំពុងបន្តនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តដំណាក់កាលទី២ ដែលគោលដៅចម្បងនៃដំណាក់កាលនេះ គឺការសម្រេចឱ្យបាននូវជំហានទី២ **គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ** ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅចុងឆ្នាំ២០០៨។ ដំណាក់កាលនេះ ត្រូវបាន និងកំពុងផ្ដោតលើការងារសំខាន់ៗដូចជា (១) ការរៀបចំ និងដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មីដែលមានភាពច្បាស់លាស់ គ្រប់ជ្រុងជ្រោយ មានសង្គតិភាព និងអនុលោមតាមស្តង់ដារអន្តរជាតិ (២) ការរៀបចំ និងដាក់ឱ្យអនុវត្តប្លង់គណនេយ្យថ្មីដែលមានភាពច្បាស់លាស់ គ្រប់ជ្រុងជ្រោយ មានសង្គតិភាព និងអនុលោមតាមស្តង់ដារអន្តរជាតិ (៣)ការរៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធី និងកិច្ចប្រតិបត្តិការការងារថ្មីក្នុងកាអនុវត្តថវិកាក្នុងក្របខ័ណ្ឌវិមជ្ឈការ និងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ។ ការងារទាំងនេះ បាន និងកំពុងរៀបចំ ហើយមានគោលដៅនឹងដាក់ឱ្យអនុវត្តសាកល្បងជំហានទី១ នៅក្នុងឆ្នាំ២០១៥ ខាងមុខ និងរំពឹងថានឹងត្រូវអនុវត្តពេញលេញនៅក្នុងឆ្នាំ២០១៧។

**១៣-** ទន្ទឹមនឹងនេះ ដើម្បីធានានិរន្តរភាពនៃការកែទម្រង់ និងដើម្បីត្រៀមលក្ខណៈសម្បត្តិសម្រាប់បណ្ដាជំហានបន្ទាប់ ***ការរៀបចំថវិកាដែលជាផ្នែកដើមនៃវដ្ដថវិកា*** (ឬអាចថានៅដើមខ្សែ) និង***ការតាមដានវាយតម្លៃលទ្ធផលដែលជាផ្នែកចុងក្រោយនៃវដ្ដថវិកា*** (ឬអាចថានៅចុងខ្សែ) ក៏ត្រូវបានចាប់ផ្ដើមកែលម្អ និងពង្រឹងជាបណ្ដើរៗ តាមរយៈការដាក់ឱ្យអនុវត្តច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅក្នុងឆ្នាំ២០០៨ ដែលក្នុងនោះ ដំណើរការនៃការរៀបចំថវិកាត្រូវបានចែកជា ៣ ដំណាក់កាលគឺ ***(១)ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (២) ការ***

*រៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំ និង (៣)ការអនុម័តថវិកាប្រចាំឆ្នាំ។* ដូច្នេះ អ្វីដែលថ្មី និងសំខាន់នៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មីនោះគឺការបន្ថែមដំណាក់កាលទី១ គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដែលជាផែនការថវិកាមានលក្ខណៈ ៣ ឆ្នាំរំកិលនៅក្នុងដំណើរការនៃការរៀបចំថវិកា និងការអនុញ្ញាតឱ្យរដ្ឋាភិបាលអនុវត្តសាកល្បងថវិកាកម្មវិធី។ ជាក់ស្តែង ការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងកម្មវិធី និងការបង្កើនគណនេយ្យភាពចំពោះសមិទ្ធកម្ម ដែលជាគោលដៅនៃដំណាក់កាលទី ៣ និងទី ៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងជាមូលដ្ឋានដ៏សំខាន់នៃប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម ដែលត្រូវបានចាប់ផ្តើមអនុវត្តសាកល្បងជាបណ្តើរៗរួមមាន *(១)ការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា ដើម្បីបង្កើនភាពច្បាស់លាស់ តម្លាភាព គណនេយ្យភាព ភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាព ក្នុងការអនុវត្តការងារ និងការប្រើប្រាស់ថវិកា (២) ការដាក់ឱ្យអនុវត្ត និងបន្តកែលម្អផែនការយុទ្ធសាស្ត្រថវិកា និង (៣)ការដាក់ឱ្យអនុវត្តសាកល្បង និងបន្តពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី។*

**១៤-** ពិតណាស់ថា ការរៀបចំថវិកាបានល្អអាចជាមូលដ្ឋានសម្រាប់ការអនុវត្តថវិកា និងការតាមដាន វាយតម្លៃលទ្ធផលបានល្អ ហើយក៏ជាមូលដ្ឋានសម្រាប់ធានាថា ថវិកាពិតជាឧបករណ៍នៃគោលនយោបាយ ឬថវិកាពិតជាបម្រើឱ្យការអនុវត្តសកម្មភាពអាទិភាព ដើម្បីធ្វើឱ្យគោលនយោបាយអាចសម្រេចបានតាមគោលដៅ ប៉ុន្តែការកែទម្រង់ការរៀបចំថវិកាមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាច្រើនជាងការកែទម្រង់ការអនុវត្តថវិកា ហើយមិនត្រឹមតែប៉ះពាល់ដល់ការកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន និងប្រព័ន្ធគ្រប់គ្រងនៅក្នុងអង្គការ

នីតិប្រតិបត្តិប៉ុណ្ណោះទេ តែថែមទាំងប៉ះពាល់ដល់ការកែសម្រួលនីតិវិធី សិទ្ធិអំណាច និងគណនេយ្យភាព ក្នុងការអនុម័តថវិការបស់អង្គការនីតិបញ្ញត្តិថែមទៀតផង។ ជាក់ស្តែងគ្មានប្រទេសណា ទោះជាប្រទេសអភិវឌ្ឍន៍ ដែលមានស្ថាប័នរឹងមាំ និងមានធនធានមនុស្សគ្រប់គ្រាន់ក៏ដោយ ក៏មិនអាចសម្រេចបានការកែទម្រង់ប្រព័ន្ធទាំងមូលក្នុងរយៈពេលតិចជាង ១០ ឆ្នាំបានទេ។ សម្រាប់កម្ពុជា ក្នុងរយៈកាល ៨ ឆ្នាំ (២០០៥-២០១២) កន្លងទៅនេះ អាចចាត់ទុកថាការកែទម្រង់បានដើរមកដល់ពាក់កណ្តាលផ្លូវហើយ ដូច្នេះកម្ពុជាអាចនឹងត្រូវការពេលវេលាប្រមាណជា ៨ ឆ្នាំ ទៀតទើបអាចសម្រេចនូវការផ្លាស់ប្តូរប្រព័ន្ធថវិកាទាំងស្រុងបាន។

**១៥-** ទោះជាយ៉ាងណា ការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តសាកល្បងថវិកាកម្មវិធីក្នុងរយៈកាល ៥ ឆ្នាំកន្លងទៅនេះ ថ្វីត្បិតតែនៅមានចំណុចខ្វះខាតដែលត្រូវបន្តកែលម្អ ពង្រឹង និងពង្រីក ប៉ុន្តែវាបានផ្តល់នូវលទ្ធផលវិជ្ជមានជាច្រើនដែលបាន និងកំពុងក្លាយជាមូលដ្ឋានដ៏សំខាន់ និងរឹងមាំសម្រាប់ការកែប្រែប្រព័ន្ធគ្រប់គ្រងថវិកាជាបណ្តើរៗដូចជា (១) ការយល់ដឹងនិងការទទួលយកការផ្លាស់ប្តូរទស្សនៈ និងទម្លាប់នៃការរៀបចំថវិកាដោយផ្តោតលើធាតុចូល (ចំនួនឥណទានដែលត្រូវយកទៅដាក់តាមមាតិកាថវិកា) ទៅជាការរៀបចំថវិកាដោយផ្តោតលើធាតុចេញ (លទ្ធផលនៃគោលនយោបាយដែលត្រូវអនុវត្ត) (២) ការបង្កើនការយកចិត្តទុកដាក់ក្នុងការរៀបចំគោលបំណងគោល-នយោបាយរបស់ក្រសួង ស្ថាប័នឱ្យបានល្អ និងឆ្លើយតបទៅនឹងគោលនយោបាយតាមវិស័យ និងគោលនយោបាយថ្នាក់ជាតិ (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

និងយុទ្ធសាស្ត្រចតុកោណ) សម្រាប់ជាអំណោះអំណាង និងការពារដើម្បីប្រកួតជាមួយគោលបំណងគោលនយោបាយអាទិភាពដទៃទៀតក្នុងការទាញយកកញ្ចប់ថវិកាដែលមានកម្រិត (៣) ការបង្កើតបាននូវកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព ព្រមទាំងអនុកម្មវិធី និងចង្កោមសកម្មភាពដែលជាយុទ្ធសាស្ត្រសម្រាប់ការអនុវត្ត និងសម្រេចឱ្យបានតាមគោលដៅនៃគោលបំណងគោលនយោបាយ (៤) ការបង្កើតបាននូវសូចនាករ និងគោលដៅទៅតាមកម្រិតនៃចង្កោមសកម្មភាព អនុកម្មវិធី និងកម្មវិធី ព្រមទាំងគោលបំណងគោលនយោបាយ ដែលជាមូលដ្ឋានសម្រាប់វាស់វែង និងតាមដានវាយតម្លៃលទ្ធផល (៥) បង្កើតបាននូវទស្សនៈនៃការរៀបចំថវិកាពហុឆ្នាំ ដើម្បីធានាចីរភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃការវិភាជថវិកា (៦) បង្កើនបានសុក្រឹតភាពក្នុងការគណនាតម្រូវការថវិកា និងការវិភាជប្រចាំឆ្នាំចំគោលដៅ និង (៧) បង្កើនបានមួយកម្រិតនូវតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវរវាងអង្គភាពម្ចាស់ថវិកា ដែលមានតួនាទីអនុវត្តសកម្មភាពផ្ទាល់ (នាយកដ្ឋានជំនាញ) និងអង្គភាពគ្រប់គ្រងថវិកា (នាយកដ្ឋានហិរញ្ញវត្ថុ) ទោះជាការតាមដានវាយតម្លៃលទ្ធផល និងការធ្វើរបាយការណ៍នៅមានចំណុចខ្វះខាតច្រើនដែលត្រូវបន្តកែលម្អក៏ដោយ។ ម៉្យាងទៀត ការបន្តពង្រឹង និងពង្រីកជាជំហានៗលើផ្នែកទាំង ២ គឺការកែលម្អជាបណ្តើរៗឈានទៅរកការផ្លាស់ប្តូរទាំងស្រុងនៃការរៀបចំថវិកា ពីការផ្អែកតែទៅលើធាតុចូល (ថវិកាមាតិកា) ទៅជាការរៀបចំថវិកាផ្អែកលើធាតុចេញ (ថវិកាលទ្ធផល ឬថវិកាសមិទ្ធកម្ម) និងការពង្រឹង និងបង្កើនជាបណ្តើរៗឈានទៅរកការអនុវត្តពេញលេញ និងគ្រប់ជ្រុងជ្រោយនូវប្រព័ន្ធតាមដានវាយតម្លៃលទ្ធផល ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ។ លើសពីនេះ រាជរដ្ឋាភិបាលក៏

បាន និងកំពុងជំរុញការអនុវត្តការកែទម្រង់ដ៏សំខាន់ និងដែលជាការកែទម្រង់ដែលមានលក្ខណៈជាប្រព័ន្ធ ព្រមទាំងបំពេញឱ្យគ្នាទៅវិញទៅមកនោះគឺ ការកែទម្រង់រដ្ឋបាល និងការកែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្រប-ខ័ណ្ឌគោលនយោបាយវិសហមជ្ឈការ និងវិមជ្ឈការ ដែលនឹងកាន់តែជួយគាំទ្រ និងជំរុញដល់ការអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម ពិសេស ប្រព័ន្ធតាមដានវាយតម្លៃលទ្ធផលនៃការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ។

**១៦-** ដូច្នេះ ទិសដៅដ៏ចម្បងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវធ្វើការ**ផ្លាស់ប្តូរជាបណ្តើរៗពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ** គឺជាការផ្លាស់ប្តូរប្រព័ន្ធទាំងមូល និងមានផលប៉ះពាល់ដល់កិច្ចប្រតិបត្តិការងារ ដល់ការប្រើប្រាស់ និងគ្រប់គ្រងធនធានមនុស្ស ដល់រចនាសម្ព័ន្ធគ្រប់គ្រង និងចាត់តាំងស្ថាប័ន និងដល់ការផ្លាស់ប្តូរការគ្រប់គ្រងដែលជាការងារស្មុគស្មាញ និងត្រូវការពេលវេលា ព្រមទាំងត្រូវការឆន្ទៈទាំងកម្រិតនយោបាយ និងបច្ចេកទេសខ្ពស់ ជាពិសេសលុះត្រាតែមានការដឹកនាំគ្រប់គ្រង និងសម្របសម្រួលការងារកែទម្រង់ប្រកបដោយភាពហ្មត់ចត់ ម៉ឺងម៉ាត់ អំណត់ និងព្យាយាមកម្រិតខ្ពស់ ព្រមទាំងមានទិសដៅ និងយុទ្ធសាស្ត្រច្បាស់លាស់ និងយន្តការគ្រប់គ្រង ត្រួតពិនិត្យជាប្រចាំប្រកបដោយភាពស័ក្តិសិទ្ធ

និងប្រសិទ្ធភាពខ្ពស់ ទើបអាចធានាសម្រេចបានជោគជ័យ។ លើសពីនេះ តម្រូវឱ្យមានកិច្ចសហការប្រកបដោយភាពជាម្ចាស់ ការទទួលខុសត្រូវខ្ពស់ និងសកម្ម-គ្រប់គ្រងពីគ្រប់តួអង្គទាំងអស់ ជាពិសេស ត្រូវធានារក្សាឱ្យបាននូវសង្គតិភាព និងភាពសុខដុមនីយកម្មរវាងការកែទម្រង់ធំៗ និងសំខាន់ៗទាំង ៣ ដែលមានលក្ខណៈជាការកែទម្រង់ប្រព័ន្ធនោះ គឺ**ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ**។

## ៤.២- បទពិសោធន៍នៃការកែទម្រង់ថវិកាកន្លងមក

**១៧**-ទោះជាប្រទេសនីមួយៗនៅលើសកលលោក អាចមានហេតុផលផ្សេងៗគ្នា និងជ្រើសរើសយកអភិក្រមផ្សេងៗគ្នាក្នុងការធ្វើការកែទម្រង់ប្រព័ន្ធគ្រប់គ្រងថវិកា ឬប្រព័ន្ធហិរញ្ញវត្ថុសាធារណៈក៏ដោយ ប៉ុន្តែបទពិសោធន៍ជាសកលបានបង្ហាញថា ប្រទេសភាគច្រើនលើសលប់បាន និងកំពុងធ្វើការកែទម្រង់ឆ្ពោះទៅរក**ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម ដែលមានលក្ខណៈវិសហមជ្ឈការ និងវិមជ្ឈការ**។ ពិតណាស់ថាការដែលប្រទេសនីមួយៗមានហេតុផល និងជ្រើសរើសអភិក្រមផ្សេងៗគ្នានោះ គឺដោយសារតែលក្ខណៈសម្បត្តិ និងស្ថានភាពនៃប្រទេសនីមួយៗ ឬ/និង ចំណុចចាប់ផ្តើមនៃប្រទេសនីមួយៗមានលក្ខណៈខុសគ្នា។ ប៉ុន្តែ អ្វីដែលប្រទេសនីមួយៗចង់បាននោះ គឺអត្ថប្រយោជន៍នៃប្រព័ន្ធនេះដែលអាចធានាឱ្យមានការគោរពនូវគោលការណ៍គ្រឹះ ១១ យ៉ាងដែលមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងដែលជាមូលដ្ឋានសម្រាប់ធានាការរក្សាវិន័យថវិកា

(រក្សាតុល្យភាព និងចីរភាព) ប្រសិទ្ធភាពវិភាជថវិកា (ជានាការវិភាជចំគោលដៅអាទិភាព) និងប្រសិទ្ធភាពបច្ចេកទេសនៃការប្រើប្រាស់ថវិកា (ជានាការប្រើប្រាស់ថវិកាប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាព)។ គោលការណ៍គ្រឹះទាំង ១១ នោះរួមមាន (១) ភាពជាអាជ្ញា (២)កាលបរិច្ឆេទមានកាលកំណត់មួយឆ្នាំ (៣)ភាពគ្រប់ជ្រុងជ្រោយ (៤) ឯកត្តភាព (៥)សកលភាព (៦)វិសេសភាព (៧) តុល្យភាព (៨) គណនេយ្យភាព (៩) តម្លាភាព (១០) ស្ថិរភាព និង (១១) សមិទ្ធកម្ម។

**១៨-** ចាប់ពីដើមទសវត្សឆ្នាំ១៩៩០ មក រដ្ឋាភិបាលនៃបណ្តាប្រទេសជាច្រើននៅលើសកលលោកបានចាប់ផ្តើមធ្វើការកែទម្រង់ប្រព័ន្ធថវិការបស់ខ្លួន ដោយបញ្ចូលទៅក្នុងវិធីសាស្ត្រនៃការរៀបចំថវិកានូវទស្សនៈ និងវិធាននៃការរៀបចំថវិកាដោយផ្តោតលើលទ្ធផលក្នុងកម្រិតណាមួយ។ ជាក់ស្តែង ដូចជាប្រទេសនូវ៉ែលហ្ស៊ីលែន កាណាដា និងចក្រភពអង់គ្លេសជាដើម ដែលបានផ្លាស់ប្តូរការគ្រប់គ្រងពីការផ្តោតការត្រួតពិនិត្យលើធាតុចូល និងធនធានទៅជាការគ្រប់គ្រងដែលមានភាពទន់ភ្លន់ និងផ្តោតជាសំខាន់លើការតាមដានវាយតម្លៃលើការសម្រេចបានលទ្ធផល ឬសមិទ្ធកម្ម ហើយដែលនិន្នាការនៃការផ្លាស់ប្តូរប្រព័ន្ធ និងការគ្រប់គ្រងនេះ ត្រូវបានបន្តរីកចម្រើនជាបន្តបន្ទាប់នៅគ្រប់តំបន់ទូទាំងពិភពលោករហូតមកដល់បច្ចុប្បន្ន។ ពិតណាស់ថា ទន្ទឹមនឹងគោលដៅប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃការប្រើប្រាស់ថវិកា ឬនៃប្រព័ន្ធគ្រប់គ្រងថវិកាទាំងមូលដែលត្រូវបានយល់ថា ជាគោលដៅចាំបាច់ត្រូវតែសម្រេចឱ្យបាននោះ ក៏ឆ្លងតាមការវិវត្តនៃវិទ្យាសាស្ត្រនយោបាយ និងសង្គម បណ្តាគោលដៅ ឬលក្ខខណ្ឌដទៃទៀតក៏ត្រូវបានរកឃើញថាចាំបាច់ និងតម្រូវឱ្យមានផងដែរ ដូចជា

គណនេយ្យភាព តម្លាភាព និងការគិតគូរជាពហុឆ្នាំជាដើម។

**១៩-** ដូច្នេះ មានន័យថា និយមន័យនៃថវិកាគឺជាឧបករណ៍នៃគោលនយោបាយ និងគោលការណ៍សំខាន់ ៣ នៃថវិកាគឺវិន័យថវិកា ប្រសិទ្ធភាពវិភាជថវិកា និងប្រសិទ្ធភាពបច្ចេកទេសនៃការប្រើប្រាស់ថវិកា គឺនៅដដែលមិនបានផ្លាស់ប្តូរទេ អ្វីដែលត្រូវបានផ្លាស់ប្តូរនោះគឺវិធីសាស្ត្រ និងយន្តការនៃការគ្រប់គ្រង និងការអនុវត្តក្នុងគោលដៅធានាឱ្យប្រព័ន្ធថវិកាពិតជាឆ្លើយតបទៅនឹងគោលការណ៍សំខាន់ទាំង ៣ និងនិយមន័យនៃថវិកាខាងលើ។ ទន្ទឹមនឹងនេះ ដោយសារមានចំណុចខ្លាំង និងចំណុចខ្សោយនៃវិធីសាស្ត្រនីមួយៗ និងអាស្រ័យទៅតាមស្ថានភាពជាក់ស្តែងនៃប្រទេសនីមួយៗ វិធីសាស្ត្រ និងប្រភេទនៃការរៀបចំថវិកាលើសពីមួយ ត្រូវបានប្រើប្រាស់នៅក្នុងប្រព័ន្ធគ្រប់គ្រងថវិកានៃប្រទេសមួយចំនួន។ ទោះជាអាចមានការហៅឈ្មោះផ្សេងៗគ្នាខ្លះក៏ដោយ តែជារួមបច្ចុប្បន្នមានវិធីសាស្ត្រ ៣ ក្នុងការរៀបចំថវិកាគឺ (១) ***ថវិកាតាមមាតិកា*** ការរៀបចំថវិកាដោយផ្អែកលើបន្ទាត់មាតិកាថវិកា (២) ***ថវិកាកម្មវិធី*** គឺជាការរៀបចំថវិកាដោយផ្អែកលើកម្មវិធី និង (៣) ***ថវិកាសមិទ្ធកម្ម*** គឺជាការរៀបចំថវិកាដោយផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម។ តាមបទពិសោធន៍ជាអន្តរជាតិត្រូវបានទទួលស្គាល់ថាមានប្រព័ន្ធគ្រប់គ្រងថវិកា ២ ប្រភេទគឺ ***(១)ប្រព័ន្ធគ្រប់គ្រងថវិកាបែបបុរាណ*** ដែលជាប្រព័ន្ធប្រើថវិកាតាមមាតិកា និងការគ្រប់គ្រងផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការខ្ពស់ និង ***(២)ប្រព័ន្ធគ្រប់គ្រងថវិកាបែបទំនើប*** ដែលជាប្រព័ន្ធប្រើវិធីសាស្ត្រថវិកាកម្មវិធីផង និងថវិកាសមិទ្ធកម្មផង ហើយការគ្រប់គ្រងផ្តោតលើធាតុចេញ (លទ្ធផល ឬសមិទ្ធកម្ម) និងមានលក្ខណៈវិមជ្ឈការ។ ប្រព័ន្ធទី ២

នេះគឺជាប្រព័ន្ធកំពុងពេញនិយមដែលប្រទេសភាគច្រើនកំពុងអនុវត្ត ឬកំពុងធ្វើការកែទម្រង់ឆ្ពោះទៅរកដូចដែលកម្ពុជាបាន និងកំពុងធ្វើដំណើរឆ្ពោះទៅរកក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដែលយុទ្ធ-សាស្ត្រនៃការឆ្ពោះទៅរកប្រព័ន្ធនោះ គឺជាកម្មវត្ថុនៃឯកសារទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធគ្រប់គ្រងថវិកានៅកម្ពុជា ២០១៣-២០២០ នេះ។

**២០-** នៅកម្ពុជា ការកែទម្រង់ប្រព័ន្ធគ្រប់គ្រងថវិកាពិតប្រាកដត្រូវបានចាប់ផ្តើមពីការដាក់ឱ្យអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅឆ្នាំ២០០៨ ដែលបានចែកការរៀបចំថវិកាជា ៣ ដំណាក់កាល គឺ ការរៀបចំផែនការយុទ្ធ-សាស្ត្រថវិកាសម្រាប់រយៈពេល ៣ ឆ្នាំរំកិល ការរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំ និងការអនុម័តថវិកាប្រចាំឆ្នាំ។ ប្រការនេះ បានតម្រូវឱ្យគ្រប់ក្រសួង ស្ថាប័នកសាងគោលបំណងគោលនយោបាយ ព្រមទាំងកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព ដែលអាចសម្រេចបាន និងឆ្លើយតបទៅនឹងគោលនយោបាយតាមវិស័យ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក៏ដូចជាយុទ្ធសាស្ត្រចតុកោណ។ ដូច្នេះ ក្រសួងស្ថាប័នបានហ្វឹកហាត់អស់ ៦ ឆ្នាំកន្លងមកហើយនូវការផ្លាស់ប្តូរពីការរៀបចំថវិកាដោយផ្តោតលើតែមាតិកាថវិកា មកជាការផ្តោតលើកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព និងគោលបំណងគោលនយោបាយដែលក្រសួង ស្ថាប័ន ចង់អនុវត្ត និងសម្រេចឱ្យបានលទ្ធផលដែលត្រូវឆ្លុះបញ្ចាំងតាមរយៈសូចនាករ និងគោលដៅ។ មានន័យថា ការរៀបចំថវិកានៅកម្ពុជាមិនត្រឹមតែត្រូវបានតម្រូវដោយច្បាប់ និងមានយន្តការសម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយតាមរយៈផែនការយុទ្ធសាស្ត្រថវិកា ៣ ឆ្នាំរំកិល ដែលជាគោលដៅនៃជំហានទី ៣ នៃកម្មវិធីកែ

ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប៉ុណ្ណោះទេ តែថែមទាំងត្រូវបានអនុវត្ត ៦ ឆ្នាំរួចមកហើយ ទោះជានៅមានចំណុចខ្វះខាតដែលត្រូវកែលម្អក៏ដោយ។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំពុងរៀបចំការត្រួតពិនិត្យ និងវាយ-តម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រថវិកានេះ ដើម្បីរៀបចំយុទ្ធសាស្ត្រកែលម្អ និងពង្រឹងឱ្យកាន់តែបានល្អប្រសើរថែមទៀត និងដែលជាចំណែកមួយនៃទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធគ្រប់គ្រងថវិកាដែលមានបង្ហាញ និងពន្យល់លម្អិតនៅក្នុងផ្នែកទី ៣ នៃឯកសារនេះ។

**២១-** ទន្ទឹមនឹងនេះ ការដាក់ឱ្យអនុវត្តសាកល្បងថវិកាកម្មវិធីពីឆ្នាំ ២០០៨ សម្រាប់ក្រសួង ៨ កន្លងមក (ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី) មិនត្រឹមតែបានបង្កើតនូវទស្សនៈ និងការយល់ដឹងអំពីសារៈសំខាន់ និងអត្ថប្រយោជន៍នៃការអនុវត្តថវិកាកម្មវិធីប៉ុណ្ណោះទេ តែថែមទាំងបង្កើតបាននូវការផ្សារភ្ជាប់រវាងកម្មវិធី និងគោលបំណងគោល-នយោបាយ និងសូចនាករសម្រាប់វាស់វែងលទ្ធផល ព្រមទាំងបង្កើនបាននូវសុក្រឹតភាពនៃការគណនាតម្រូវការចំណាយ ប្រសិទ្ធភាពនៃការវិភាជថវិកា និងគណនេយ្យភាព និងការទទួលខុសត្រូវរវាងម្ចាស់ថវិកា (អ្នកប្រើប្រាស់ថវិកាផ្ទាល់- នាយកដ្ឋានជំនាញ) និងអ្នកគ្រប់គ្រងថវិកា (សម្របសម្រួលការប្រើប្រាស់ថវិកា- នាយកដ្ឋានហិរញ្ញវត្ថុ)ទៀតផង។ ម៉្យាងទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើការត្រួតពិនិត្យវាយតម្លៃការអនុវត្តកន្លងមកជាមួយនឹងក្រសួងទាំង៨ ហើយ

ជាលទ្ធផលបានបង្ហាញថា ទោះជានៅមានចំណុចខ្វះខាតដែលត្រូវកែលម្អ ក៏ដោយ ក៏ការសាកល្បងនេះបានកសាងនូវមូលដ្ឋានដ៏រឹងមាំ សម្រាប់ការពង្រឹង និងពង្រីក ដើម្បីឈានទៅផ្ទេរទាំងស្រុងពីប្រព័ន្ធថវិកាបច្ចុប្បន្ន ទៅរកប្រព័ន្ធថវិកាដោយផ្ដោតលើលទ្ធផល ឬសមិទ្ធកម្មជាមួយនឹងប្រព័ន្ធគ្រប់គ្រង ដែលមានលក្ខណៈវិសហមជ្ឈការ និងវិមជ្ឈការបានដោយជោគជ័យ ហើយដែលយុទ្ធសាស្ត្រពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី និងយុទ្ធសាស្ត្រនៃការកែទម្រង់ថវិកាទាំងមូលមានបង្ហាញ និងពន្យល់លម្អិតនៅផ្នែកទី ៣ នៃឯកសារនេះ។

**២២-** លើសពីនេះទៅទៀត បទពិសោធន៍បានបង្ហាញឱ្យឃើញថា ទោះជាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយជាការងារសំខាន់ និងដើមខ្សែក៏ដោយ តែភាពជោគជ័យនៃប្រព័ន្ធថវិកាផ្អែកលើលទ្ធផលជាមួយនឹងប្រព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការ និងវិមជ្ឈការ ក៏អាស្រ័យទៅលើផ្នែកកណ្ដាលខ្សែ និងចុងខ្សែដែរ នោះគឺការអនុវត្តថវិកា ឬការគ្រប់គ្រងហិរញ្ញវត្ថុដែលត្រូវធ្វើតុល្យភាពអំណាចរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នជំនាញ ក៏ដូចជារវាងនាយកដ្ឋានហិរញ្ញវត្ថុនិងនាយកដ្ឋានជំនាញ ដើម្បីបង្កើតគណនេយ្យភាព និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់ និងប្រកបដោយប្រសិទ្ធភាព ព្រមទាំងការតាមដានវាយតម្លៃលទ្ធផលសម្រេចបាន ដែលជាផ្នែកដ៏សំខាន់ចុងក្រោយនៃវដ្តថវិកានៅក្នុងប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬសមិទ្ធកម្ម និងជាធាតុចូលដ៏សំខាន់សម្រាប់វដ្តបន្ទាប់។ ម្យ៉ាងទៀត ប្រព័ន្ធនេះតម្រូវឱ្យមានការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងសិទ្ធិអំណាច និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់ និងមានសង្គតិភាពទៅនឹងរចនាសម្ព័ន្ធនៃគោលនយោបាយដែលរួមមាន

គោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មវិធី ព្រមទាំងចង្កោមសកម្ម-ភាព ដែលមានសូចនាករ និងគោលដៅសម្រាប់វាស់វែងលទ្ធផលនៅគ្រប់កម្រិតនីមួយៗ។ ដូច្នេះ ដើម្បីអាចអនុវត្តប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផលបានពេញលេញ លុះត្រាតែមានព័ត៌មានច្បាស់លាស់ គ្រប់ជ្រុងជ្រោយ លម្អិតសុក្រឹត និងទាន់ពេលវេលា ទើបអាចយកមកវិភាគ វាយតម្លៃ និងធ្វើជាមូលដ្ឋានសម្រាប់ការវិភាជថវិកា និងត្រួតពិនិត្យ តាមដាន វាយតម្លៃលទ្ធផលបាន។ ផ្អែកលើបទពិសោធន៍ និងការយល់ឃើញទាំងនេះហើយ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំត្រៀមលក្ខណៈ ដើម្បីដាក់ឱ្យអនុវត្តអង្គភាពថវិកា ដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី ដាក់ឱ្យអនុវត្តនីតិវិធីនៃកិច្ចប្រតិបត្តិការអនុវត្តថវិកាថ្មីក្នុងក្របខ័ណ្ឌនៃការដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ដែលមានបង្ហាញ និងពន្យល់លម្អិតនៅក្នុងផ្នែកទី ៣ នៃឯកសារនេះ។

## V- បណ្តាកត្តាកំណត់ជោគជ័យនៃការកែទម្រង់

២៣- ក្នុងការអនុវត្តយុទ្ធសាស្ត្រខាងលើឆ្ពោះទៅរកទិសដៅនៃប្រព័ន្ធថវិកាឆ្នាំ២០២០ ប្រាកដជានឹងជួបប្រទះនូវការលំបាក និងបញ្ហាប្រឈមមួយចំនួនជាមិនខាន ដែលតាមបទពិសោធន៍បណ្តាចំណុចគន្លឹះ និងជាកត្តាកំណត់ជោគជ័យដែលត្រូវយកចិត្តទុកដាក់នោះគឺរួមមានដូចខាងក្រោម÷

***១- ត្រូវបង្កើនភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពនៃប្រព័ន្ធ:*** ពិតណាស់ថាការបាត់បង់ ឬការសម្រេចបាននូវភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពទាប គឺភាគច្រើនដោយសារភាពមិនច្បាស់លាស់ ឬភាពទន់ខ្សោយនៃប្រព័ន្ធ ដែលរួមមានរចនាសម្ព័ន្ធគោលនយោបាយ រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន និងការកំណត់សិទ្ធិអំណាច និងការទទួលខុសត្រូវពុំបានច្បាស់លាស់ និងប្រកបដោយតម្លាភាព និងគណនេយ្យភាពដែលទំនាក់ទំនងនេះមានបង្ហាញនៅក្នុងដ្យាក្រាម២។ ដូច្នេះទោះជាមានការលំបាក និងស្មុគស្មាញខ្លះ ដែលអាចនឹងកើតឡើងក្នុងការរៀបចំរចនាសម្ព័ន្ធទាំងនេះ និងការកំណត់ឱ្យបានច្បាស់លាស់ប្រកបដោយតម្លាភាព និងគណនេយ្យភាពនៅគ្រប់កម្រិតក៏ដោយ ក៏ពុំមានជម្រើសផ្សេងទេក្នុងការបង្កើនភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពនោះ ហេតុនេះដាច់ខាតត្រូវតែពុះពារដោយចាប់ផ្តើមពីផ្នែក ឬកន្លែងដែលងាយមុន ហើយជាបណ្តើរៗឈានទៅកែលម្អ ឬកែសម្រួលទាំងស្រុង ស្របតាមយុទ្ធសាស្ត្រនៃការកែទម្រង់ជាជំហានៗ និងជាដំណាក់ៗ។

***២- ត្រូវបង្កើនភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាពនៃការតាមដានវាយតម្លៃ និងការប្រើប្រាស់លទ្ធផលនៃលទ្ធផល និងសមិទ្ធកម្ម:*** ការតាមដានវាយ

តម្លៃលទ្ធផល និងសមិទ្ធកម្មគឺជាផ្នែកចុងក្រោយនៃវដ្តថវិកាមែន តែគឺជាផ្នែកដ៏សំខាន់បំផុតសម្រាប់ប្រព័ន្ធថវិកាកម្មវិធី និងប្រព័ន្ធថវិកាសមិទ្ធកម្ម ពិសេសការគ្រប់គ្រងផ្អែកលើលទ្ធផលនិងសមិទ្ធកម្មជាមួយនឹងវិសហមជ្ឈការ និងវិមជ្ឈការខ្ពស់។ លើសពីនេះ ទាមទារឱ្យមានការផ្លាស់ប្តូរពីការផ្តោតការត្រួតពិនិត្យតែទៅលើធាតុចូល (ថវិកា សម្ភារៈ ឧបករណ៍ និងរបាយការណ៍ហិរញ្ញវត្ថុ) មកជាការតាមដានវាយតម្លៃលើធាតុចេញ (សកម្មភាព គោលដៅនៃសូចនាករ លទ្ធផលនៃសកម្មភាព និងរបាយការណ៍លទ្ធផល)ទើបលទ្ធផលនៃការតាមដានវាយតម្លៃនោះអាចប្រើប្រាស់បានប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាព និងអាចបង្កើនប្រសិទ្ធភាពវិភាជ និងប្រសិទ្ធភាពបច្ចេកទេសនៃការប្រើប្រាស់ថវិកាបាន។ ដូច្នេះ ទោះជាមានការលំបាក និងស្មុគស្មាញខ្លះ ដែលអាចកើតឡើងក្នុងការផ្លាស់ប្តូរនេះក៏ដោយ ជាពិសេស អាចពាក់ព័ន្ធដល់ការកំណត់ និងបែងចែកមុខងារឱ្យបានច្បាស់លាស់រវាងអាជ្ញាធរសវនកម្មជាតិ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច អគ្គាធិការដ្ឋានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសវនកម្មផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន ក៏ពុំមានជម្រើសផ្សេងដែរសម្រាប់ការបង្កើនប្រសិទ្ធភាពវិភាជ និងប្រសិទ្ធភាពបច្ចេកទេសនៃការប្រើប្រាស់ថវិកា ព្រមទាំងសម្រាប់ការបន្តកែលម្អជាប្រចាំនូវសកម្មភាព កម្មវិធី និងគោលបំណងគោលនយោបាយ ដើម្បីធានាការឆ្លើយតបទៅនឹងគោលដៅនៃគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។ លើសពីនេះ គួរតែបង្កើតឱ្យមានយន្តការច្បាស់លាស់ និងរឹងមាំនៅកម្រិតរដ្ឋាភិបាលដើម្បីតាមដានវាយតម្លៃលទ្ធផល និងសមិទ្ធកម្មរបស់គ្រប់ក្រសួង ស្ថាប័នប្រចាំឆ្នាំ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាដែលមានគោលបំណងគោលនយោបាយ កម្មវិធី ព្រមទាំងសូចនាករ និង

គោលដៅច្បាស់លាស់ និងត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលចាប់ពីឆ្នាំ២០១៥ តទៅ។

***៣- ត្រូវបង្កើនផលិតភាពការងារតាមរយៈការបង្កើនសមត្ថភាពមន្ត្រី និងស្ថាប័ន:*** បញ្ហាផលិតភាពការងារនឹងក្លាយជាបញ្ហាសំខាន់សម្រាប់កម្ពុជា ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន ជាពិសេសក្នុងពេលដែលសេដ្ឋកិច្ចកម្ពុជាកាន់តែទំនើបកម្ម និងសមាហរណកម្មនៅក្នុងតំបន់ និងពិភពលោក។ ទំនើបកម្មសេដ្ឋកិច្ចមានន័យថា ត្រូវការកម្រិតជំនាញកាន់តែខ្ពស់ ហើយសមាហរណកម្មសេដ្ឋកិច្ចមានន័យថា អនុញ្ញាតឱ្យពលកម្មហូរចូលមកដោយសេរី ពេលនោះមិនថាតែបុគ្គលទេ សូម្បីតែស្ថាប័នក៏ត្រូវប្រឈមនឹងការប្រកួតប្រជែងដែរ ដូច្នេះផលិតភាពទាបនឹងមិនអាចប្រកួតប្រជែងបានទេ។ ហេតុនេះ ដាច់ខាតត្រូវតែមានគោលនយោបាយ និងយុទ្ធសាស្ត្រកសាងសមត្ថភាព ច្បាស់លាស់ គ្រប់ជ្រុងជ្រោយ និងរយៈពេលវែង ទើបអាចធានាមិនត្រឹមតែសម្រាប់បម្រើឱ្យការអនុវត្តទិសដៅនៃការកែទម្រង់នេះទេ តែសម្រាប់ចីរភាពការងារយូរអង្វែងរបស់ប្រទេសជាតិទាំងមូល។

***៤- ត្រូវបង្កើនឆន្ទៈ ការប្តេជ្ញា ភាពជាម្ចាស់ ភាពសកម្មគ្រប់គ្រង និងការទទួលខុសត្រូវនៅគ្រប់កម្រិត:*** ជាការពិត តាមបទពិសោធន៍ឃើញថា ទាំងកម្រិតថ្នាក់ដឹកនាំ កម្រិតគ្រប់គ្រង និងកម្រិតជំនាញនៅតាមក្រសួង ស្ថាប័ននៅពុំទាន់មានឆន្ទៈ ការប្តេជ្ញាចិត្ត ភាពជាម្ចាស់ ភាពសកម្មគ្រប់គ្រង និងការទទួលខុសត្រូវខ្ពស់ចំពោះការកែទម្រង់នៅឡើយ ហើយពេលខ្លះកម្រិតទាំង៣ នេះក៏នៅពុំទាន់មានទស្សនៈរួម និងអាចស្វែងរកការឯកភាពគ្នាបានឆាប់នៅឡើយទេ នៅតាមក្រសួង ស្ថាប័ន ទោះជាមានបង្កើតយន្តការគ្រប់គ្រាន់តាំងពីកម្រិតក្រសួង

ស្ថាប័ន (ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមក្រសួង ស្ថាប័ន) និងថ្នាក់អន្តរក្រសួង (គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ) រួចហើយក៏ដោយ។ ដូច្នេះ ចាំបាច់ត្រូវតែពង្រឹងយន្តការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលនេះឡើងវិញ ដើម្បីបង្កើនឆន្ទៈ ការប្តេជ្ញាចិត្ត ភាពជាម្ចាស់ ភាពសកម្មគ្រប់គ្រង និងការទទួលខុសត្រូវខ្ពស់ចំពោះការកែទម្រង់ដែលជាកត្តាសំខាន់និងចាំបាច់សម្រាប់ការអនុវត្តទិសដៅយុទ្ធសាស្ត្រនេះប្រកបដោយជោគជ័យ។

*៥- ត្រូវបង្កើនកិច្ចសហការ និងសម្របសម្រួលឱ្យកាន់តែស័ក្តិសិទ្ធ និងប្រសិទ្ធភាពរវាងការកែទម្រង់ធំៗ និងសំខាន់ព្រមទាំងមានចរិតជាការកែទម្រង់ប្រព័ន្ធទាំង ៣ (ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការកែទម្រង់រដ្ឋបាល):* ពិតណាស់ថាកិច្ចសហការ និងសម្របសម្រួលកន្លងមកពិតជាមាន ប៉ុន្តែនៅតែត្រូវការពង្រឹង និងត្រូវការបង្កើតយន្តការឱ្យកាន់តែច្បាស់លាស់ ទាំងកម្រិតបច្ចេកទេសគ្រប់គ្រង និងដឹកនាំ ព្រោះមិនត្រឹមតែដើម្បីធានាសង្គតិភាពប៉ុណ្ណោះទេ តែវាជាកត្តាកំណត់ជោគជ័យរបស់ការកែទម្រង់នីមួយៗក៏ដូចជាការកែទម្រង់ទាំងអស់របស់រាជរដ្ឋាភិបាល។

## VI- សេចក្តីសន្និដ្ឋាន

**២៤-** ដូច្នេះ ការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជាបាន និងកំពុងដើរលើផ្លូវត្រូវ ហើយស្របទៅនឹងនិន្នាការការកែទម្រង់ជាសកល ព្រមទាំងបាន និងកំពុងផ្តល់ផ្លែផ្កា និងវឌ្ឍនភាពគួរជាទីលើកទឹកចិត្ត។ ទន្ទឹមនឹងនេះ វឌ្ឍនភាព និងបទពិសោធន៍ ដែលទទួលបានកន្លងមកពិតជាបានផ្តល់នូវទស្សនៈ ចំណេះដឹង និងមូលដ្ឋានដ៏រឹងមាំ ធ្វើឱ្យយើងមានជំនឿថា យើងពិតជាមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ការបន្តអនុវត្តការកែទម្រង់ប្រព័ន្ធថវិកាប្រកបដោយជោគជ័យ តាមទិសដៅយុទ្ធសាស្ត្រដែលបានគូសបញ្ជាក់ខាងលើ ដើម្បីឈានទៅសម្រេចឱ្យបាននូវការផ្លាស់ប្តូរប្រព័ន្ធថវិកាកម្ពុជាទាំងស្រុង ពីប្រព័ន្ធថវិកាតាមបន្ទាត់មាតិកា និងការគ្រប់គ្រងផ្តោតលើធាតុចូល ទៅជាប្រព័ន្ធថវិកាកម្មវិធី និងការគ្រប់គ្រងផ្តោតលើលទ្ធផលនិងសមិទ្ធកម្ម ជាមួយនឹងវិសហមជ្ឈការនិងវិមជ្ឈការនៅ ឆ្នាំ២០២០ ដែលជាមូលដ្ឋានដ៏សំខាន់ ចាំបាច់ និងថែមទាំងជាកត្តាកំណត់ជោគជ័យនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល។

**២៥-**ពិតណាស់ថា យើងក៏នឹងត្រូវជួបប្រទះនូវបញ្ហាប្រឈម ការលំបាក និងភាពស្មុគស្មាញមួយចំនួន ពិសេសសម្រាប់ការកែទម្រង់ទាំង ៣ ដែលមានលក្ខណៈជាការកែទម្រង់ប្រព័ន្ធ ប៉ុន្តែបើយើងគិតអំពីអត្ថប្រយោជន៍ដែលយើងទទួលបាន ហើយនឹងបន្តទទួលបាននោះគឺពិតជាមានតម្លៃលើសលប់ទៅនឹងការបង់ថ្លៃទាំងនេះ “ ***គ្មានលទ្ធផលណាដែលបានមកដោយមិនមានការបង់ថ្លៃនោះទេ ហើយក៏គ្មានការកែទម្រង់ណាដែលសម្រេចបានដោយមិនមានការលះបង់នោះដែរ*** ” ម៉្យាងទៀតយើងក៏គ្មានជម្រើសដែរ ដូចសម្តេចអគ្គមហា

សេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាមានប្រសាសន៍ថា " ***កែទម្រង់រស់ មិនកែទម្រង់នឹងស្លាប់*** " ។ ទន្ទឹមនឹងនេះ ក្នុងស្ថានភាពវិវត្តយ៉ាងលឿននៃសេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យា ពិសេសនាសម័យទំនើបកម្ម និងសមាហរណកម្មនេះបាន និងកំពុងជំរុញឱ្យទាំងបុគ្គល ទាំងស្ថាប័ន ទាំងវិស័យឯកជន ទាំងវិស័យសាធារណៈ ទាំងកម្រិតជាតិ ទាំងកម្រិតតំបន់ និងទាំងកម្រិតអន្តរជាតិ មិនត្រឹមតែត្រូវធ្វើប្រតិបត្តិការប្រកបដោយភាពរស់រវើក ព្រមទាំងត្រៀមលក្ខណៈជានិច្ចសម្រាប់ការកែលម្អ និងកែទម្រង់ឱ្យកាន់តែប្រសើរឡើងជាប្រចាំប៉ុណ្ណោះទេ តែថែមទាំងត្រូវគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយ និងទូលំទូលាយហួសពីព្រំសីមារបស់ខ្លួនក្នុងការវិភាគ និងការធ្វើសេចក្តីសម្រេចចិត្តទើបអាចធានាស្ថិរភាព និងនិរន្តរភាពបាន។

**២៦-** ទោះជាយ៉ាងណា ដូចបានគូសបញ្ជាក់មកខាងលើថា លទ្ធផល និងបទពិសោធន៍ដែលទទួលបាន ជាមួយនឹងការអនុវត្តហ្វឹកហាត់សាកល្បងបានយ៉ាងល្អកន្លងមក ពិតជាបញ្ជាក់ពីសមត្ថភាព និងការត្រៀមលក្ខណៈគ្រប់គ្រាន់សម្រាប់ប្រែក្លាយទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៣-២០២០ នេះឱ្យក្លាយជាមគ្គុទ្ទេសក៍ពិតប្រាកដក្នុងការបន្តអនុវត្តការកែទម្រង់ថវិកាជាជំហានៗ ឆ្ពោះទៅរកការសម្រេចឱ្យបាននូវការផ្លាស់ប្តូរប្រព័ន្ធថវិកាតាមមាតិកាបច្ចុប្បន្នទៅជាប្រព័ន្ធថវិកាកម្មវិធី និងការគ្រប់គ្រងផ្តោតលើលទ្ធផល និងសមិទ្ធកម្ម ដែលជាប្រព័ន្ធប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាព ដើម្បីឈានទៅធានារក្សាឱ្យបាននូវគោលការណ៍ថវិកាជាមូលដ្ឋាន ៣ គឺវិន័យថវិកា (រក្សាតុល្យភាព និងចីរភាព) ប្រសិទ្ធភាពវិភាជថវិកា (ធានាការវិភាជចំគោលដៅអាទិភាព) និង

ប្រសិទ្ធភាពបច្ចេកទេសនៃការប្រើប្រាស់ថវិកា (ធានាការប្រើប្រាស់ថវិកាប្រកបដោយភាពស័ក្តិសិទ្ធ និងប្រសិទ្ធភាព) ព្រមទាំងគោលការណ៍គ្រឹះនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំង ១១ ដូចបានគូសបញ្ជាក់ខាងលើ ដែលជាមូលដ្ឋានសំខាន់ និងចាំបាច់សម្រាប់ការរក្សាស្ថិរភាព និរន្តរភាពនៃថវិកា នៃហិរញ្ញវត្ថុសាធារណៈ និងនៃម៉ាក្រូសេដ្ឋកិច្ច ដើម្បីធានាកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សម្រាប់បម្រើឱ្យគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដែលជាទិសដៅគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។